East Insurance Plc.

# ក្រុមហ៊ុន អេស អិនស្វូរិន ភីអិលស៊ី

East Insurance Plc.

# ការផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍ប្រចាំឆ្នាំ សម្រាប់ឆ្នាំ ២០២៥

East Insurance Plc.

# ការផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍ប្រចាំឆ្នាំ ២០២៥
## របស់ក្រុមហ៊ុនអេស អិនសួរិន ភីអិលស៊ី

## I.ព័ត៌មានអប្បបរមានៃរបាយការណ៍ប្រចាំឆ្នាំ

### ១. ព័ត៌មានសង្ខេបអំពីអាជីវកម្ម

ក្រុមហ៊ុនធានារ៉ាប់រង អេស អិនសួរិន ភីអិលស៊ី (East Insurance PLC) គឺជាក្រុមហ៊ុនធានារ៉ាប់រងទូទៅដែលបានទទួលអាជ្ញាបណ្ណនៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧ ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងទទួលអាជ្ញាបណ្ណលេខ ០៤០ ន.ធ.ក./អជ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២ របស់និយ័តករធានារ៉ាប់រងកម្ពុជា។ នៅឆ្នាំ ២០២៥ តាមរយៈការខិតខំប្រឹងប្រែងរបស់គណៈគ្រប់គ្រង និងការប្រកាន់ខ្ជាប់នូវការណែនាំរបស់និយ័តករធានារ៉ាប់រងកម្ពុជាដោយមានការរួមចំណែកពីបុគ្គលិកទាំងអស់ លទ្ធផលការងាររបស់យើងក្នុងឆ្នាំ **២០២៥** សម្រេចបាននូវការកើនឡើងគួរឱ្យកត់សម្គាល់ ។ ទន្ទឹមនឹងនេះ យើងរកបានបុព្វលាភដុលលើសពី ២ លានដុល្លារអាមេរិកជាលើកដំបូង ដោយបុព្វលាភដុលរបស់ក្រុមហ៊ុនយើងកើនឡើងជាលំដាប់។

នាឆ្នាំ ២០២៦ខាងមុខនេះ យើងនឹងបន្តផ្តល់សេវាធានារ៉ាប់រង បន្ថែមទៀតសម្រាប់រូបវន្តបុគ្គល ឬ សហគ្រាសទាំងឡាយ និងជាពិសេសសហគ្រាសដែលផ្តល់មូលនិធិដោយប្រទេសចិន។

### ២. សាររបស់ប្រធានក្រុមប្រឹក្សាភិបាល

លោក TAN WENCHAO

ប្រធានក្រុមប្រឹក្សាភិបាល

នៅឆ្នាំ ២០២៥ ក្រុមហ៊ុនយើងបានប្រកាន់ខ្ជាប់នូវបេសកកម្មដើមរបស់វិស័យធានារ៉ាប់រង ដោយអនុវត្តប្រតិបត្តិការយ៉ាងមានស្ថិរភាព គ្រប់គ្រងហានិភ័យយ៉ាងតឹងរឹង បម្រើដល់សេដ្ឋកិច្ច និងការធានាសុខុមាលភាពរបស់ប្រជាពលរដ្ឋ ដែលនាំឱ្យលទ្ធផលអាជីវកម្មរបស់យើងកាន់តែប្រសើរជាបន្តបន្ទាប់។ សូមថ្លែងអំណរគុណចំពោះទំនុកចិត្តរបស់ភាគទុនិក ការគាំទ្រពីអតិថិជន និងការខិតខំបំពេញភារកិច្ចដោយការទទួលខុសត្រូវរបស់បុគ្គលិកទាំងអស់។

នាឆ្នាំ ២០២៦ យើងនឹងបន្តប្រកាន់ខ្ជាប់នូវគោលការណ៍រក្សាស្ថេរភាពជាមូលដ្ឋាន និងជំរុញការរីកចម្រើន បន្តជំរុញការកែទម្រង់ និងបំពេញទំនួលខុសត្រូវសង្គម និងជំរុញការអភិវឌ្ឍប្រកបដោយគុណភាព

East Insurance Plc.

## ៣. សាររបស់អគ្គនាយក

លោក HUANG YOUFENG

អគ្គនាយកប្រតិបត្តិ (CEO)

នៅឆ្នាំ ២០២៥ ក្រុមហ៊ុនបានផ្តោតយ៉ាងស៊ីជម្រៅលើអាជីវកម្មនៃជានារ៉ាប់រងទូទៅ ដោយបន្តកែលម្អរចនាសម្ព័ន្ធអាជីវកម្ម លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាកម្ម ពង្រឹងការទទួលខុសត្រូវក្នុងការដោះស្រាយសំណងធានារ៉ាប់រង និងពង្រឹងការគ្រប់គ្រងហានិភ័យ ដើម្បីការពារមូលដ្ឋានសុវត្ថិភាពនៃប្រតិបត្តិការ ហើយបានសម្រេចគោលដៅអាជីវកម្មប្រចាំឆ្នាំដោយជោគជ័យ។ សូមថ្លែងអំណរគុណចំពោះការណែនាំរបស់ក្រុមប្រឹក្សាភិបាល ទំនុកចិត្តរបស់អតិថិជន និងការខិតខំបំពេញការងាររបស់សហការីទាំងអស់។

នាឆ្នាំ ២០២៦ យើងនឹងបន្តផ្តោតលើអាជីវកម្មស្នូល លើកកម្ពស់គុណភាព និងប្រសិទ្ធភាព បង្កើតនវានុវត្តន៍លើផលិតផល និងសេវាកម្ម ពង្រឹងការគ្រប់គ្រងប្រកបដោយភាពលម្អិត និងវិជ្ជាជីវៈ បង្កើនសមត្ថភាពប្រកួតប្រជែង និងជំរុញឱ្យការប្រតិបត្តិការរបស់ក្រុមហ៊ុនឈានទៅកាន់កម្រិតថ្មីមួយទៀត។

East Insurance Plc.

# ៤. ព័ត៌មានហិរញ្ញវត្ថុសង្ខេប

## ព័ត៌មានសង្ខេបអំពីប្រតិបត្តិការអាជីវកម្មក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយ

## ទិន្នន័យពាក់ព័ន្ធនឹងលទ្ធផលអាជីកម្ម

| អេស អិនស្សូរិន ភីអិលស៊ី<br>ស្ថានភាព 3ឆ្នាំ 2023 2024 2025<br>របាយការណ៍ចំណេញរឺខាត | | | | | | |
|---|---|---|---|---|---|---|
| | បានធ្វើសវនកម្ម<br>31-Dec-25 | | បានធ្វើសវនកម្ម<br>31-Dec-24 | | បានធ្វើសវនកម្ម<br>31-Dec-23 | |
| | US$ | KHR$'000 | US$ | KHR$'000 | US$ | KHR$'000 |
| | | 4.011 | | | | |
| បុព្វលាភដុល | 2,377,657 | 9,536,782 | 1,393,312 | 5,672,173 | 646,637 | 2,641,512 |
| បុព្វលាភជានាវ៉ាប់រងបន្ត | (2,118,770) | (8,498,386) | (1,354,108) | (5,512,574) | (423,586) | (1,730,349) |
| | | | | | | |
| ចំណូលបុព្វលាភសុទ្ធ | 258,887 | 1,038,396 | 39,204 | 159,599 | 223,051 | 911,163 |
| | | | | | | |
| ចំណូលផ្សេងៗ | 631,032 | 2,531,069 | 516,451 | 2,102,472 | 410,791 | 1,678,081 |
| បម្រែបម្រួលដុលនៃបំណុលកិច្ចសន្យា | (27,227) | (109,207) | 59,391 | 241,781 | (54,376) | (222,126) |
| ចំណាយរដ្ឋបាល | (584,079) | (2,342,741) | (291,019) | (1,184,738) | (261,939) | (1,070,021) |
| ចំណាយហិរញ្ញវត្ថុ | (5,673) | (22,754) | (2,089) | (8,504) | (424) | (1,732) |
| | | | | | | |
| ចំណេញមុនបង់ពន្ធ | 272,940 | 1,094,763 | 321,938 | 1,310,610 | (262,363) | (1,071,753) |
| ចំណាយពន្ធ | (110,515) | (443,276) | (94,430) | (384,425) | (50,300) | (205,476) |
| | | | | | | |
| ចំណេញសម្រាប់ការិយបរិច្ឆេទ | 162,425 | 651,487 | 227,508 | 926,185 | (312,663) | (1,277,229) |
| | | | | | | |
| ខាតលម្អិតផ្សេងៗ - លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (95,206) | - | (474,468) | | |
| ចំណេញ/( ខាត )លម្អិតសរុបសម្រាប់ការិយបរិច្ឆេទ | 162,425 | 556,281 | 227,508 | 451,717 | | |

East Insurance Plc.

# ទិន្នន័យពាក់ព័ន្ធនឹងស្ថានភាពហិរញ្ញវត្ថុ

**អេស អិនស្វរិន ភីអិលស៊ី**

ស្ថានភាព 3ឆ្នាំ 2023 2024 2025

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

| | បានធ្វើសវនកម្ម 31-Dec-25 | | បានធ្វើសវនកម្ម 31-Dec-24 | | បានធ្វើសវនកម្ម 31-Dec-23 | |
|---|---|---|---|---|---|---|
| | US$ | KHR$'000 | US$ | KHR$'000 | US$ | KHR$'000 |
| | | 4.013 | | | | |
| ទ្រព្យសកម្ម | | | | | | |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | 2,197 | 8,817 | - | - | - | - |
| សិទ្ធិក្នុងការប្រើប្រាស់លើទ្រព្យសកម្ម | 70,182 | 281,640 | 20,427 | 82,219 | 31,569 | 128,958 |
| ទ្រព្យវិនិយោគ | - | - | - | - | 1,379,500 | 5,635,258 |
| ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ | 700,000 | 2,809,100 | 700,000 | 2,817,500 | 700,000 | 2,859,500 |
| គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេង ៗ | 695,417 | 2,790,708 | 253,417 | 1,020,003 | 1,806,648 | 7,380,157 |
| សាច់ប្រាក់ និងសមតុល្យនៅក្នុងធនាគារ | 8,077,547 | 32,415,196 | 7,844,719 | 31,574,994 | 4,545,871 | 18,569,883 |
| **ទ្រព្យសកម្មសរុប** | 9,545,343 | 38,305,461 | 8,818,563 | 35,494,716 | 8,463,588 | 34,573,756 |
| **មូលធន និងបំណុល** | | | | | | |
| **មូលធន** | | | | | | |
| ដើមទុន | 7,000,000 | 28,000,000 | 7,000,000 | 28,000,000 | 7,000,000 | 28,595,000 |
| មូលធនបំពេញ | 1,250,000 | 5,028,250 | 1,000,000 | 4,025,000 | 1,000,000 | 4,085,000 |
| ចំណេញរក្សាទុក/(ខាតបង្គរ) | 123,305 | 502,874 | (39,120) | (148,613) | (266,628) | (1,089,175) |
| លម្អៀងពីការប្តូររូបិយប័ណ្ណបម្រុងទុក | - | 70,949 | - | 166,155 | | |
| | 8,373,305 | 33,602,073 | 7,960,880 | 32,042,542 | 7,733,372 | 31,590,825 |
| បំណុលរយៈពេលខ្លី | | | | | | |
| បំណុលកិច្ចសន្យាធានារ៉ាប់រង | 133,682 | 536,466 | 106,455 | 428,481 | 70,265 | 287,033 |
| បំណុលភតិសន្យា | 72,323 | 290,232 | 21,335 | 85,874 | 31,764 | 129,754 |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេង ៗ | 943,681 | 3,786,991 | 716,921 | 2,885,607 | 597,325 | 2,440,073 |
| បំណុលពន្ធបច្ចុប្បន្ន | 22,352 | 89,699 | 12,972 | 52,212 | 30,862 | 126,071 |
| បំណុលសរុប | 1,172,038 | 4,703,388 | 857,683 | 3,452,174 | 730,216 | 2,982,931 |
| មូលធន និងបំណុលសរុប | 9,545,343 | 38,305,461 | 8,818,563 | 35,494,716 | 8,463,588 | 34,573,756 |

## អនុបាតហិរញ្ញវត្ថុសំខាន់ៗ

អនុបាត ULAE ចាប់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥

| All Class of Business | 2023 | 2024 | 2025 |
|---|---|---|---|
| Claim Department Expense | 12,600 | 12,600 | 17,040 |
| Gross Claim Payment | 36,163 | 41,134 | 203,166 |
| ULAE Ratio | 35% | 31% | 13% |
| Selected ULAE Ratio | | | 13% |

អនុបាតសំណងសរុប (ULR) សម្រាប់អនុបាតសំណងព្យាករណ៍ដុល និងអនុបាតសំណងព្យាករណ៍សុទ្ធ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

| Class of Business | Gross of Reinsurance | Net of Reinsurance |
|---|---|---|
| Individual Auto Insurance | 43.00% | 43.00% |
| Individual Property Insurance | 19.00% | 19.00% |
| Individual Engineer Insurance | 20.00% | 20.00% |
| Individual Personal Accident Insurance | 27.00% | 27.00% |
| Group Personal Accident Insurance | 27.00% | 27.00% |
| Group Medical Insurance | 27.00% | 27.00% |
| Individual Miscellaneous insurance | 20.00% | 20.00% |

អនុបាតចំណាយរក្សាបណ្ណសន្យារ៉ាប់រង

| All Class of Business | 2023 | 2024 | 2025 |
|---|---|---|---|
| Maintenance Expense | 32,299 | 22,101 | 26,660 |
| Gross Earned Premium | 641,543 | 1,395,653 | 1,824,124 |
| ME Ratio | 5.03% | 1.58% | 1.46% |
| Selected ME Ratio | | | 2% |

## ទិន្នន័យនិន្នាការនៃទីផ្សារធានារ៉ាប់រង។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រុមហ៊ុនបានរក្សាកំណើនអាជីវកម្មប្រកបដោយស្ថេរភាព និងបន្តពង្រីកចំណែកទីផ្សាររបស់ខ្លួន។ បុព្វលាភធានារ៉ាប់រងដុល (Gross Written Premium) សម្រេចបាន ១,៨៨ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៤ និងកើនឡើងដល់ ២,២១ លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០២៥ ដែលតំណាងឱ្យកំណើនគួរឱ្យកត់សម្គាល់។ សម្រាប់ឆ្នាំ ២០២៦ ក្រុមហ៊ុនបានកំណត់គោលដៅសម្រេចបុព្វលាភធានារ៉ាប់រងដុល ចំនួន ៣លានដុល្លារអាមេរិក តាមរយៈការពង្រីកមូលដ្ឋានអតិថិជន ការអភិវឌ្ឍផលិតផលថ្មី និងការពង្រឹងគុណភាពសេវាកម្ម។

ជាមួយនឹងសក្តានុពលនៃការវិនិយោគបរទេស និងការរីកចម្រើននៃសហគ្រាសចិននៅកម្ពុជា ក្រុមហ៊ុនរំពឹងថាតម្រូវការធានារ៉ាប់រងនឹងបន្តកើនឡើង ដែលនឹងផ្តល់ឱកាសល្អសម្រាប់ការអភិវឌ្ឍអាជីវកម្មរយៈពេលវែង។

## II. ព័ត៌មានអំពីអាជីវកម្ម

### ១. ក្រុមហ៊ុន

ក្រុមហ៊ុនធានារ៉ាប់រង អេស អិនស្វូរិន ភីអិលស៊ី (East Insurance PLC) គឺជាក្រុមហ៊ុនធានារ៉ាប់រងដែលបានទទួលអាជ្ញាបណ្ណនៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧ ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងទទួលអាជ្ញាបណ្ណលេខ ០៤០ ន.ធ.ក./អជ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២ របស់និយ័តករធានារ៉ាប់រងកម្ពុជា។ បច្ចុប្បន្នយើងមានទីស្នាក់ការកណ្តាលនៅទីក្រុងភ្នំពេញ។

ក្រុមហ៊ុនរបស់យើងទទួលបានអាជ្ញាប័ណ្ណសម្រាប់ផលិតផលធានារ៉ាប់រងចម្រុះ រួមមានខ្សែអាជីវកម្មផលិតផលធានារ៉ាប់រងទ្រព្យសម្បត្តិ វិស្វកម្ម គ្រោះថ្នាក់បុគ្គល សុខភាព យានយន្ត និងគ្រោះថ្នាក់ផ្សេងៗ ។ នេះជាមូលដ្ឋានគ្រឹះដ៏ល្អសម្រាប់ការចូលរួមចំណែកផ្គត់ផ្គង់តម្រូវការធានារ៉ាប់រងក្នុងទីផ្សារ និងការអភិវឌ្ឍន៍ផែនការទីផ្សាររបស់ក្រុមហ៊ុន។

ក្រុមហ៊ុន អេស អិនស្វូរិន ភីអិលស៊ី ជឿជាក់ថាក្រុមហ៊ុននឹងផ្តល់ជម្រើសសេវាកម្មធានារ៉ាប់រងកាន់តែប្រសើរឡើងទៅដល់អតិថិជនទាំងអស់ ជាពិសេសសហគ្រាសចិននៅកម្ពុជា ។

### ២. ផលិតផលធានារ៉ាប់រង

ក្រុមហ៊ុន អេស អិនស្វូរិន ភីអិលស៊ី រៀបចំរចនាសម្ព័ន្ធផលិតផលធានារ៉ាប់រងរបស់ខ្លួន ដើម្បីបំពេញតម្រូវការជាក់លាក់របស់សហគ្រាសចិនដែលវិនិយោគនៅក្នុងប្រទេសកម្ពុជា។ ក្រុមហ៊ុនមានសំណុំផលិតផលចម្រុះ រួមមានខ្សែអាជីវកម្មផលិតផលធានារ៉ាប់រងទ្រព្យសម្បត្តិ វិស្វកម្ម គ្រោះថ្នាក់បុគ្គល សុខភាព យានយន្ត និងគ្រោះថ្នាក់ផ្សេងៗ ។

ក្នុងអំឡុងពេលរបាយការណ៍ពីឆ្នាំ ២០២៣ ដល់ឆ្នាំ ២០២៥ ក្រុមហ៊ុនបានបង្ហាញនូវរចនាសម្ព័ន្ធសំណុំផលិតផលដែលមានតុល្យភាព។ ចង្កោមផលិតផលធានារ៉ាប់រងទ្រព្យសម្បត្តិ នៅតែជាខ្សែអាជីវកម្មលេចធ្លោ ដោយរួមចំណែក ៨២% នៃបុព្វលាភដុលសរុបក្នុងឆ្នាំ២០២៣ ៥០% ក្នុងឆ្នាំ ២០២៤ និង ៥៣% ក្នុងឆ្នាំ២០២៥ ។ ចង្កោមផលិតផលធានារ៉ាប់រងលើវិស្វកម្មមានការបម្រែបម្រួលជាមួយនឹងការកើនឡើងគួរឱ្យកត់សម្គាល់រហូតដល់ ៤៣% ក្នុងឆ្នាំ២០២៤ ខណៈពេលដែលចង្កោមផលិតផលគ្រោះថ្នាក់ផ្សេងៗបានបង្ហាញពីកំណើនគួរឱ្យកត់សម្គាល់ ដោយឈានដល់ ៣៣% ក្នុងឆ្នាំ ២០២៥ ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងធ្វើពិពិធកម្មរបស់ក្រុមហ៊ុន។ ខ្សែអាជីវកម្មផ្សេងទៀត រួមទាំងចង្កោមផលិតផលធានារ៉ាប់រងយានយន្ត គ្រោះថ្នាក់បុគ្គល និងសុខភាព បានចូលរួមចំណែកតែមានសមាមាត្រតិចតួច។

## ភាគរយនៃចំណែកនៃបុព្វលាភសរុបរបស់ក្រុមហ៊ុន អេស អិនសួរិន ភីអិលស៊ី តាមខ្សែអាជីវកម្ម

| ខ្សែអាជីវកម្ម (LOB) | ២០២៥ | ២០២៤ | ២០២៣ |
|---|---|---|---|
| យានយន្ត | ១% | ២% | ៤% |
| វិស្វកម្ម | ១២% | ៤៣% | ៨% |
| ផ្សេងៗ | ៣៣% | ២% | 0%~ |
| គ្រោះថ្នាក់បុគ្គល | ១% | ៣% | ៥% |
| ទ្រព្យសម្បត្តិ | ៥៣% | ៥០% | ៨២% |
| សុខភាព | 0%~ | 0%~ | 0%~ |

ទីផ្សារធានារ៉ាប់រងនៅកម្ពុជា កំពុងបន្តមានការរីកចម្រើនជាលំដាប់ ដោយសារកត្តាជំរុញចម្បងមួយចំនួនមានដូចជា ការអភិវឌ្ឍសេដ្ឋកិច្ច កំណើនសំណង់មូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធ និងកំណើននៃការយល់ដឹងអំពីការការពារហានិភ័យ។ ទន្ទឹមនឹងការអភិវឌ្ឍន៍វិស័យសំណង់ ផលិតកម្ម និងពាណិជ្ជកម្ម តម្រូវការធានារ៉ាប់រងទ្រព្យសម្បត្តិបានកើនឡើងជាបន្តបន្ទាប់ ហើយធានារ៉ាប់រងអត្ថប្រយោជន៍បុគ្គលិក (ធានារ៉ាប់រងសុខភាព និងគ្រោះថ្នាក់បុគ្គល) ក៏មាននិន្នាការកើនឡើងផងដែរ។ បន្ថែមពីនេះ ជាមួយនឹងការកែលម្អប្រព័ន្ធបទប្បញ្ញត្តិ និងកិច្ចសន្យាពាណិជ្ជកម្ម តម្រូវការធានារ៉ាប់រងទំនួលខុសត្រូវក៏កំពុងមានកើនឡើងជាលំដាប់ ហើយទីផ្សារមានទំនោរជ្រើសរើសក្រុមហ៊ុនធានារ៉ាប់រងដែលមានស្ថេរភាពហិរញ្ញវត្ថុល្អ និងសមត្ថភាពសេវាកម្មខ្ពស់។ ក្រៅពីនេះ គម្រោង "ផ្លូវមួយខ្សែក្រវ៉ាត់មួយ" របស់ចិននៅកម្ពុជា ក៏បានជួយជំរុញតម្រូវការធានារ៉ាប់រងវិស្វកម្ម និងប្រភេទធានារ៉ាប់រងពាក់ព័ន្ធផ្សេងៗផងដែរ។

នៅក្នុងបរិបទនៃទីផ្សារដូចបានបកស្រាយខាងលើនេះ ក្រុមហ៊ុនបានអនុម័តយុទ្ធសាស្ត្រផលិតផលដែលមានស្ថេរភាព ដែលផ្តោតលើចំណុចទីផ្សារសំខាន់ៗ ក្នុងការផ្តល់ដំណោះស្រាយធានារ៉ាប់រងគ្រប់ជ្រុងជ្រោយ ដោយផ្តោតជាពិសេសលើការគាំទ្រគម្រោងហេដ្ឋារចនាសម្ព័ន្ធ សំណង់ និងគម្រោងវិនិយោគដែលទាក់ទងនឹងសហគ្រាសចិនដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។ ក្រុមហ៊ុនធានាថាផលិតផលទាំងអស់អនុលោមតាមច្បាប់និងបទប្បញ្ញត្តិដែលនិយ័តករតម្រូវ និងស្របតាមស្តង់ដារអន្តរជាតិដែលពាក់ព័ន្ធ។ លើសពីនេះ ក្រុមហ៊ុននឹងបន្តធ្វើឱ្យខ្សែអាជីវកម្មផលិតផលរបស់ខ្លួនប្រសើរឡើង ដើម្បីសម្រេចបាននូវតុល្យភាពសមស្របរវាងកំណើនប្រាក់ចំណេញ និងការប្រឈមនឹងហានិភ័យ ខណៈពេលដែលកំពុងបង្កើនគុណភាពសេវាកម្ម និងបង្កើតតម្លៃកាន់តែប្រសើរដល់អតិថិជនរបស់ខ្លួន។

## ៣. ការចាប់ដៃគូ និងប្រព័ន្ធចែកចាយ

ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារជាក់ស្តែងដែលផ្តោតលើសហគ្រាសមធ្យម និងធំរបស់ប្រទេសចិន និងបុគ្គលជាអ្នកវិនិយោគជនជាតិចិន ក្រុមហ៊ុនបានបង្កើតយុទ្ធសាស្ត្រចែកចាយដោយ

សហការជាមួយបណ្តាញអាជីវកម្មចិនដែលមានស្រាប់នៅក្នុងប្រទេសកម្ពុជា។
យុទ្ធសាស្ត្រអនុវត្តៈ
១ បង្កើតភាពជាដៃគូយុទ្ធសាស្ត្រជាមួយសមាគមពាណិជ្ជកម្មចិននៅកម្ពុជា និងក្រុមហ៊ុនវិនិយោគចិន នានាដែលមិនស្ថិតនៅក្នុងនោះ។
២ ប្រើប្រាស់ប្រព័ន្ធលក់ផ្ទាល់ ទៅដល់អតិថិជនគោលដៅ។
៣ ការកំណត់រចនាសម្ព័ន្ធលក់តាមភ្នាក់ងារធានារ៉ាប់រង និងក្រុមហ៊ុនកំរៃជើងសារ ។

បច្ចុប្បន្ន ក្រុមហ៊ុនបានបង្កើតទំនាក់ទំនងសហប្រតិបត្តិការយ៉ាងរឹងមាំជាមួយក្រុមហ៊ុនធានារ៉ាប់រងបន្ត (Reinsurance Companies) ទាំងក្នុងប្រទេសកម្ពុជា និងនៅទីក្រុងហាណូយ តាមរយៈកិច្ចសន្យាធានារ៉ាប់រងបន្ត (Treaty Reinsurance Agreements)។

លើសពីនេះ ក្រុមហ៊ុនក៏មានកិច្ចសហប្រតិបត្តិការធានារ៉ាប់រងបន្តជាបណ្តោះអាសន្ន (Facultative Reinsurance) ជាមួយក្រុមហ៊ុនធានារ៉ាប់រងឈានមុខគេរបស់ប្រទេសចិន រួមមាន PICC, Ping An, CPIC និងក្រុមហ៊ុនធានារ៉ាប់រងធំៗផ្សេងទៀតដែលស្ថិតក្នុងចំណាត់ថ្នាក់កំពូលរបស់ប្រទេសចិន។

ក្រុមហ៊ុនប្រកាន់យុទ្ធសាស្ត្រលក់ផ្ទាល់ (Direct Sales Model) ជាចម្បង ដោយផ្តោតលើការកសាងទំនាក់ទំនងរយៈពេលវែងជាមួយអតិថិជន និងរក្សាកម្មសិទ្ធិអតិថិជននៅក្នុងក្រុមហ៊ុនផ្ទាល់។ យុទ្ធសាស្ត្រនេះជួយបង្កើនភាពស្មោះត្រង់របស់អតិថិជន កាត់បន្ថយការពឹងផ្អែកលើភ្នាក់ងារ និងធានាបាននូវការអភិវឌ្ឍអាជីវកម្មប្រកបដោយចីរភាព។

## ៤. អតិថិជន

បច្ចុប្បន្នមូលដ្ឋានអតិថិជនរបស់ក្រុមហ៊ុនគឺជាអាជីវកម្មដែលមានម្ចាស់ជាជនជាតិចិន និងបុគ្គលិកជនជាតិចិន។ ក្រុមហ៊ុនផ្តោតជាសំខាន់លើសហគ្រាសចិន និងវិនិយោគិនចិនដែលកំពុងប្រតិបត្តិការនៅកម្ពុជា ដោយសហការយ៉ាងជិតស្និទ្ធជាមួយសភាពាណិជ្ជកម្មចិន និងសហគមន៍ធុរកិច្ចចិនក្នុងស្រុក។

### យុទ្ធសាស្ត្រអតិថិជន

ការផ្តល់សេវាកម្ម៖ ក្រុមហ៊ុនបានបំពាក់បំប៉នបុគ្គលិកផ្នែកលក់ និងផ្នែកសេវាកម្មដែលប្រើប្រាស់ភាសាចិនជាចម្បង ដើម្បីសម្រួលដល់ការប្រឹក្សា និងការដោះស្រាយសំណង។
ផលិតផលគោលដៅ៖ ការរចនាផលិតផលធានារ៉ាប់រងដែលស្របតាមស្តង់ដារ និងតម្រូវការរបស់វិនិយោគិនចិន ។
កិច្ចការពារអតិថិជន៖ ផ្តល់ជូននូវយន្តការដោះស្រាយវិវាទ និងការការពារសិទ្ធិអតិថិជនដែលស្របតាម

ច្បាប់ស្តីពីការធានារ៉ាប់រងនៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះរួមបញ្ចូលទាំងការផ្តល់ព័ត៌មានច្បាស់លាស់ជាភាសាចិន។

ពេលខាងមុខ ក្រុមហ៊ុននឹងបន្តអភិវឌ្ឍផលិតផលធានារ៉ាប់រងដែលឆ្លើយតបនឹងតម្រូវការអតិថិជន កែលម្អប្រព័ន្ធសេវាកម្ម និងពង្រីកមូលដ្ឋានអតិថិជន ដើម្បីសម្រេចបាននូវកំណើនប្រកបដោយចីរភាព និងបង្កើនតម្លៃរយៈពេលវែងសម្រាប់អតិថិជន និងភាគីពាក់ព័ន្ធទាំងអស់។

## III. ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម

### ១. រចនាសម្ព័ន្ធក្រុមហ៊ុន




### ក) ក្រុមប្រឹក្សាភិបាល

1. ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការកំណត់ទិសដៅយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន ព្រមទាំងតែងតាំង ត្រួតពិនិត្យ និងកំណត់ប្រាក់ឈ្នួលសម្រាប់អគ្គនាយកប្រតិបត្តិ (CEO) និងថ្នាក់ដឹកនាំជាន់ខ្ពស់ផ្សេងៗ។
2. ក្រុមប្រឹក្សាភិបាលធានាថាក្រុមហ៊ុនប្រតិបត្តិការដើម្បីផលប្រយោជន៍ល្អបំផុតរបស់ម្ចាស់ភាគហ៊ុន តាមរយៈការអនុម័តសេចក្តីសម្រេចហិរញ្ញវត្ថុសំខាន់ៗ ដូចជា ថវិកា ការរួមបញ្ចូលក្រុមហ៊ុន និងការទិញយកអាជីវកម្ម ព្រមទាំងការបង្កើតគោលនយោបាយសំខាន់ៗ។
3. ក្រុមប្រឹក្សាភិបាលមានកាតព្វកិច្ចជាអ្នកទុកចិត្តខ្ពស់បំផុតក្នុងការការពារទ្រព្យសម្បត្តិក្រុមហ៊ុន ធានាការអនុលោមតាមច្បាប់ និងស្តង់ដារសីលធម៌ ព្រមទាំងគ្រប់គ្រងហានិភ័យសំខាន់ៗដែលអង្គភាពអាចប្រឈមមុខ។

East Insurance Plc.

4. សមាជិកក្រុមប្រឹក្សាភិបាលត្រូវបានជ្រើសរើស និងតែងតាំងដោយផ្អែកលើគុណវុឌ្ឍិវិជ្ជាជីវៈ បទពិសោធន៍ សមត្ថភាពដឹកនាំ កេរ្តិ៍ឈ្មោះ និងភាពសមស្របទៅនឹងតម្រូវការអាជីវកម្មរបស់ក្រុមហ៊ុន ព្រមទាំងអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងលក្ខខណ្ឌដែលកំណត់ដោយនិយ័តករជានារ៉ាបរងកម្ពុជា។

## ប្រវត្តិរូបសង្ខេបរបស់ក្រុមប្រឹក្សាភិបាល

លោក TAN WENCHAO

### ប្រធានក្រុមប្រឹក្សាភិបាល

ជនជាតិចិន | ប្រុស

មានបទពិសោធន៍ក្នុងតួនាទីជាអ្នកគ្រប់គ្រងជាន់ខ្ពស់ និងមានបទពិសោធន៍សម្បូរបែបក្នុងការបំពេញតួនាទីជាប្រធានក្រុមប្រឹក្សាភិបាល។

លោក WANG JUNFENG

### សមាជិកក្រុមប្រឹក្សាភិបាល

ជនជាតិចិន | ប្រុស

មានបទពិសោធន៍ការងារជាច្រើនឆ្នាំនៅកម្ពុជា ជាមួយនឹងជំនាញលេចធ្លោក្នុងការគ្រប់គ្រងធនធានមនុស្ស ។

លោកស្រី ZHANG FEN

### សមាជិកក្រុមប្រឹក្សាភិបាល

ជនជាតិចិន | ស្រី

បញ្ចប់ការសិក្សាផ្នែកច្បាប់ពីសាកលវិទ្យាល័យ Wuhan។

មានបទពិសោធន៍ក្នុងតួនាទីជាអ្នកគ្រប់គ្រង សមត្ថភាពវិភាគខ្ពស់ ជំនាញគ្រប់គ្រងឆ្នើម ។

លោកស្រី LI XI

**សមាជិកឯករាជ្យនៃក្រុមប្រឹក្សាភិបាល**

ជនជាតិចិន | ស្រី

មានសញ្ញាបត្រអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ ជាមួយនឹងបទពិសោធន៍សិក្សានៅបរទេស និងបទពិសោធន៍ជាន់ខ្ពស់យ៉ាងទូលំទូលាយក្នុងវិស័យធានារ៉ាប់រង។

លោក ស៊ុយ សុខរស្មី ( SUY SOKRAKSMEY )

**សមាជិកឯករាជ្យនៃក្រុមប្រឹក្សាភិបាល**

ជនជាតិខ្មែរ | ប្រុស

ជាអ្នកជំនាញហិរញ្ញវត្ថុដែលមានវិញ្ញាបនបត្រទទួលស្គាល់នៅកម្ពុជានិងបរទេស មានជំនាញបច្ចេកទេសខ្ពស់ និងចំណេះដឹងស៊ីជម្រៅអំពីហិរញ្ញវត្ថុនិង អាជីវកម្មធានារ៉ាប់រង។

លោកស្រី JIANG LEI

**សមាជិកឯករាជ្យនៃក្រុមប្រឹក្សាភិបាល**

ជនជាតិចិន | ស្រី

ទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកការគ្រប់គ្រងអន្តរជាតិពីសាកលវិទ្យាល័យ Loughborough និងសញ្ញាបត្រផ្នែកព័ត៌មានអាជីវកម្មពីសាកលវិទ្យាល័យ Middlesex។ មានបទពិសោធន៍វិជ្ជាជីវៈយ៉ាងសម្បូរបែបក្នុងវិស័យធានារ៉ាប់រង និងធនាគារ។

លោក MAO CHENEN

**សមាជិកឯករាជ្យនៃក្រុមប្រឹក្សាភិបាល**

ជនជាតិចិន | ប្រុស

មានសញ្ញាបត្រ MBA ពីសាកលវិទ្យាល័យ Liège  និងមានបទពិសោធន៍ភាពជាអ្នកដឹកនាំដែលបានបង្ហាញរួចមកហើយក្នុងតួនាទីជាប្រធានសភាពាណិជ្ជកម្ម។

East Insurance Plc.

## ខ) គណៈគ្រប់គ្រង

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការដឹកនាំ និងគ្រប់គ្រងប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុន អនុវត្តយុទ្ធសាស្ត្រ និងគោលនយោបាយដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល ព្រមទាំងធានាថាសកម្មភាពអាជីវកម្មត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព តម្លាភាព និងអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

<u>ប្រវត្តិរូបសង្ខេបរបស់គណៈគ្រប់គ្រង</u>

លោក HUANG YOUFENG

**អគ្គនាយកប្រតិបត្តិ (CEO)**

ជនជាតិចិន | ប្រុស

បរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុពីសាកលវិទ្យាល័យ Renmin នៃប្រទេសចិន។ ជាអ្នកជំនាញធានារ៉ាប់រងដែលមានបទពិសោធន៍ច្រើនឆ្នាំក្នុងការគ្រប់គ្រងនៅក្រុមហ៊ុនធានារ៉ាប់រងឈានមុខមួយរបស់ប្រទេស ចិន។ មានជំនាញក្នុងវិនិច្ឆ័យសំរេចចិត្ត ក្នុងការគ្រប់គ្រងនៃក្រុមហ៊ុនធានារ៉ាប់រង។

លោក សួស វិបុល (SOUS VIBOL)

**អគ្គនាយករង (Deputy CEO)**

ជនជាតិខ្មែរ | ប្រុស

បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម (BBA) ផ្នែកគ្រប់គ្រងទេសចរណ៍ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង (National University of Management)។

ទទួលបានវិញ្ញាបនបត្រជំនាញការលក់វិជ្ជាជីវៈ (Professional Selling Skills) ពីសហព័ន្ធនិយោជក និងសមាគមអាជីវកម្មកម្ពុជា (CAMFEBA)។

## ២. របាយការណ៍របស់គណៈកម្មាធិការ

### ក) គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការសវនកម្មស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាភិបាល ហើយមានភារកិច្ចសំខាន់ក្នុងការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ការត្រួតពិនិត្យ និងគ្រប់គ្រងសវនកម្មទាំងខាងក្នុង និងខាងក្រៅ ការពិនិត្យប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យការបង្ហាញព័ត៌មាន ព្រមទាំងទទួលខុសត្រូវចំពោះក្រុមប្រឹក្សាភិបាល។

<u>សមិទ្ធផលការងារប្រចាំឆ្នាំ</u>

ក្នុងឆ្នាំនេះ គណៈកម្មាធិការបានរៀបចំកិច្ចប្រជុំពិសេសចំនួន ៤ លើក ដើម្បីពិភាក្សា និងអនុម័តសំណើពាក់ព័ន្ធនឹងហិរញ្ញវត្ថុ សវនកម្ម និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។ គណៈកម្មាធិការបានពិនិត្យ និងផ្ទៀងផ្ទាត់របាយការណ៍ហិរញ្ញវត្ថុតាមកាលកំណត់ ត្រួតពិនិត្យការបំពេញភារកិច្ចរបស់សវនករខាងក្រៅ និងការអនុវត្តសវនកម្មខាងក្នុង ព្រមទាំងជំរុញការកែតម្រូវចំណុចខ្វះខាតនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។ ជាទូទៅ ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានលក្ខណៈស្តង់ដារ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមានប្រសិទ្ធភាពល្អ។

### ខ) គណៈកម្មាធិការវិនិយោគ

គណៈកម្មាធិការវិនិយោគ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាភិបាល ដែលទទួលខុសត្រូវក្នុងការសម្របសម្រួល និងគ្រប់គ្រងការវិនិយោគមូលនិធិរបស់ក្រុមហ៊ុន ការគ្រប់គ្រងហានិភ័យវិនិយោគ និងការពិនិត្យអនុម័តផែនការវិនិយោគ ដោយទទួលខុសត្រូវចំពោះក្រុមប្រឹក្សា ភិបាល។ នៅឆ្នាំ ២០២៥ ក្រុមហ៊ុនបានវិនិយោគតែទៅលើទ្រព្យសកម្មប្រភេទប្រាក់បញ្ញើមានកាលកំណត់នៅធនាគារប៉ុណ្ណោះ។

<u>សមិទ្ធផលការងារប្រចាំឆ្នាំ</u>

ពេញមួយឆ្នាំ គណៈកម្មាធិការបានពិនិត្យ និងអនុម័តប្រតិបត្តិការវិនិយោគលើប្រាក់បញ្ញើស្របតាមបទប្បញ្ញត្តិ ដោយជ្រើសរើសធនាគារដៃគូដែលមានគុណភាព គ្រប់គ្រងអត្រាការប្រាក់ និងហានិភ័យនៃការទូទាត់សងប្រាក់បញ្ញើ។ មូលនិធិទាំងអស់ត្រូវបានដាក់បញ្ញើដោយស្របច្បាប់ និងមានសុវត្ថិភាព ហើយប្រាក់ដើម និងការប្រាក់ទាំងអស់ត្រូវបានទទួលមកវិញពេញលេញតាមកាលកំណត់។ ក្រុមហ៊ុនសម្រេចបាននូវចំណូលថេរប្រកបដោយស្ថិរភាព ខណៈដែលហានិភ័យវិនិយោគសរុបស្ថិតនៅក្នុងកម្រិតអាចគ្រប់គ្រងបាន។

## ៣. របាយការណ៍អំពីអភិបាលកិច្ចសាជីវកម្ម

### ក. សមិទ្ធផលគ្រប់គ្រងឆ្នាំ ២០២៥

នៅឆ្នាំ ២០២៥ ក្រុមគ្រប់គ្រងក្រុមហ៊ុនបានអនុវត្តតាមច្បាប់ និងលក្ខន្តិកៈ ដោយផ្តោតលើគោលដៅអាជីវកម្មប្រចាំឆ្នាំ បន្តកែលម្អអភិបាលកិច្ច និងពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។ ប្រតិបត្តិការក្រុមហ៊ុនមានសណ្តាប់ធ្នាប់ល្អ សមត្ថភាពគ្រប់គ្រងហានិភ័យកាន់តែរឹងមាំ គុណភាព និងប្រសិទ្ធភាពប្រតិបត្តិការបន្តរក្សាកម្រិតល្អ។

### ខ. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលឆ្នាំ ២០២៥

នៅឆ្នាំ ២០២៥ ក្រុមប្រឹក្សាភិបាលបានអនុវត្តតួនាទីយ៉ាងត្រឹមត្រូវ និងធ្វើសេចក្តីសម្រេចតាមច្បាប់។ បានរៀបចំកិច្ចប្រជុំសរុប ៦ ដង ដោយដំណើរការស្របច្បាប់ និងអនុលោមតាមលក្ខន្តិកៈ។ ប្រធានបទសំខាន់រួមមាន ផែនការអាជីវកម្ម ថវិកា វិនិយោគ និងការកែប្រែបទប្បញ្ញត្តិ។

### គ. ស្ថានភាពគ្រប់គ្រងឆ្នាំ ២០២៥

ក្រុមគ្រប់គ្រងស្នូលមានស្ថិរភាព មិនមានការផ្លាស់ប្តូរបុគ្គលិកជាន់ខ្ពស់។ ក្រុមគ្រប់គ្រងបច្ចុប្បន្នមានបទពិសោធន៍ និងសមត្ថភាពគ្រប់គ្រាន់ ដើម្បីបន្តដឹកនាំប្រតិបត្តិការក្រុមហ៊ុនឱ្យមានស្ថិរភាព។

## IV. ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម

### ១) ដើមទុន និងកម្រិតសាធនភាព

ក្រុមហ៊ុនបានអនុវត្តយ៉ាងតឹងរឹងតាមច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងដើមទុន និងកម្រិតសាធនភាព។ ក្រុមហ៊ុនបានបន្តតាមដាន និងពិនិត្យស្ថានភាពសាធនភាពជាប្រចាំត្រីមាស ដើម្បីធានាការអនុលោមតាមតម្រូវការរបស់អាជ្ញាធរត្រួតពិនិត្យ។
ក្នុងឆ្នាំនេះ កម្រិតសាធនភាពរបស់ក្រុមហ៊ុននៅគ្រប់ត្រីមាសទាំងអស់ស្ថិតនៅលើកម្រិត ១២០% ឡើងទៅ ដោយអនុលោមតាមតម្រូវការបទប្បញ្ញត្តិយ៉ាងពេញលេញ។ ក្រុមគ្រប់គ្រងបានយកចិត្តទុកដាក់ខ្ពស់ក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងដើមទុន និងសាធនភាព ដើម្បីធានាស្ថិរភាពហិរញ្ញវត្ថុ និងសមត្ថភាពទូទាត់របស់ក្រុមហ៊ុន។
ក្នុងអំឡុងរយៈពេលរាយការណ៍ មិនមានការផ្លាស់ប្តូរដែលមានលក្ខណៈសំខាន់ចំពោះដើមទុន និងកម្រិតសាធនភាពឡើយ ហើយស្ថានភាពសាធនភាពសរុបនៅតែមានស្ថិរភាព និងស្របតាមបទប្បញ្ញត្តិជានិច្ច។

## ២) ការវិនិយោគ

ក្រុមហ៊ុនបានអនុវត្តសកម្មភាពវិនិយោគដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធ។ ក្នុងអំឡុងឆ្នាំរាយការណ៍ ក្រុមហ៊ុនបានវិនិយោគតែទៅលើប្រាក់បញ្ញើមានកាលកំណត់ (Fixed Deposit) នៅតាមស្ថាប័នហិរញ្ញវត្ថុដែលមានការអនុញ្ញាតស្របច្បាប់ ហើយមិនមានការ វិនិយោគលើឧបករណ៍ហិរញ្ញវត្ថុ ឬទ្រព្យសកម្មប្រភេទផ្សេងទៀតឡើយ។

យុទ្ធសាស្ត្រវិនិយោគរបស់ក្រុមហ៊ុនផ្តោតលើការរក្សាសុវត្ថិភាពដើមទុន ការធានានាសាច់ប្រាក់ងាយស្រួល និងការទទួលបានចំណូលការប្រាក់ប្រកបដោយស្ថិរភាព។

សំពៀតវិនិយោគត្រូវបានគ្រប់គ្រង និងត្រួតពិនិត្យជាប្រចាំ ដើម្បីធានានាការអនុលោមតាមគោលនយោបាយផ្ទៃក្នុង និងបទប្បញ្ញត្តិពាក់ព័ន្ធ។

ហានិភ័យវិនិយោគសំខាន់ៗរួមមានហានិភ័យអត្រាការប្រាក់ និងហានិភ័យឥណទានរបស់ស្ថាប័នទទួលប្រាក់បញ្ញើ។ ក្រុមហ៊ុនបានអនុវត្តវិធានការត្រួតពិនិត្យសមស្របដើម្បីកាត់បន្ថយហានិភ័យទាំងនេះ។

សម្រាប់រយៈពេលបីឆ្នាំខាងមុខ ក្រុមហ៊ុនមានផែនការបន្តវិនិយោគលើប្រាក់បញ្ញើមានកាលកំណត់តែប៉ុណ្ណោះ ហើយមិនមានគម្រោងពង្រីកទៅកាន់ប្រភេទវិនិយោគផ្សេងទៀតនាពេលបច្ចុប្បន្នឡើយ។

មិនមានបម្រែបម្រួលសំខាន់ណាមួយលើយុទ្ធសាស្ត្រវិនិយោគ ឬរចនាសម្ព័ន្ធសំពៀតវិនិយោគក្នុងអំឡុងឆ្នាំរាយការណ៍ឡើយ។

## ៣) ប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង

### ទិន្នន័យឆ្នាំ 2024

**សេចក្តីសង្ខេប**

ប្រាក់បម្រុងធានារ៉ាប់រង និងប្រាក់បម្រុងសំណងធានារ៉ាប់រងគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ត្រូវបានគណនាដោយផ្អែកលើព័ត៌មានដែលទទួលបានគិតត្រឹមថ្ងៃទី៨ ខែមករា ឆ្នាំ២០២៥ ដូចបានបង្ហាញក្នុងតារាងទី១ ខាងក្រោម៖

តារាងទី១៖ ប្រាក់បម្រុងបុព្វលាភធានារ៉ាប់រង និងប្រាក់បម្រុងសំណងធានារ៉ាប់រងគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| Liabilities | Reserve Item | Gross Amount | Reinsurance Amount | Net Amount |
|---|---|---|---|---|
| Premium Liabilities | UPR | 1,061,934 | 967,895 | 94,039 |
| | URR | 363,125 | 133,872 | 229,252 |
| | AURR | - | - | 143,644 |
| | **Subtotal** | **1,061,934** | **967,895** | **237,683** |
| Claim Liabilities | IBNR | 96,059 | 83,643 | 12,415 |
| | RBNS | - | - | - |
| | ULAE | 63,399 | - | 63,399 |
| | **Subtotal** | **159,457** | **83,643** | **75,814** |
| **Total** | | **1,221,391** | **1,051,538** | **305,067** |

យោងតាមតារាងទី១ ពិនិត្យឃើញថា ប្រាក់បម្រុងហានិភ័យមិនទាន់ផុតសុពលភាពសុទ្ធ ( Net Unexpired Risk Reserve ) ចំនួន 229,252 ដុល្លារអាមេរិក ដែលភាគច្រើនរួមចំណែកមកពីការធានារ៉ាប់រងការធានារ៉ាប់រងវិស្វកម្ម និងទ្រព្យសម្បត្តិ។ ក្រុមហ៊ុន **អេស អ៊ិនសួរិន ភីអិលស៊ី** មានប្រាក់បម្រុងហានិភ័យមិនទាន់ផុតសុពលភាពបន្ថែម ( AURR ) សរុបចំនួន 143,644 ដុល្លារអាមេរិក។ សម្រាប់ប្រាក់បម្រុងសំណងធានារ៉ាប់រងសុទ្ធ ( Net Claim Liability ) នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២៤ មានចំនួន 75,814 ដុល្លារអាមេរិក ដែលភាគច្រើនរួមចំណែកពីការធានារ៉ាប់រងវិស្វកម្ម និងទ្រព្យសម្បត្តិ។ ប្រាក់បម្រុងសំណងធានារ៉ាប់រងសុទ្ធសម្រាប់ការធានារ៉ាប់រងទ្រព្យសម្បត្តិតំណាងឱ្យ 56% នៃបុព្វលាភធានារ៉ាប់រងបាត់ទុកជាចំណូលសុទ្ធសរុប ( Net Earned Premium )។

East Insurance Plc.

ទិន្នន័យឆ្នាំ ២០២៥

### ផ្នែកទី ២៖ សេចក្តីសង្ខេប

ប្រាក់បម្រុងធានារ៉ាប់រង និងប្រាក់បម្រុងសំណងធានារ៉ាប់រងគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ត្រូវបានគណនាដោយផ្អែកលើព័ត៌មានដែលទទួលបានគិតត្រឹមថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៦ ដូចបានបង្ហាញក្នុងតារាងទី១ ខាងក្រោម៖

តារាងទី១៖ ប្រាក់បម្រុងបុព្វលាភធានារ៉ាប់រង និងប្រាក់បម្រុងសំណងធានារ៉ាប់រងគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

| Liabilities | Reserve Item | Gross Amount | Reinsurance Amount | Net Amount |
|---|---|---|---|---|
| Premium Liabilities | UPR | 1,448,121 | 1,407,194 | 40,926 |
| | URR | 355,305 | 278,450 | 76,855 |
| | AURR | 0 | 0 | 43,987 |
| | **Subtotal** | **1,448,121** | **1,407,194** | **84,914** |
| Claim Liabilities | IBNR | 122,145 | 106,244 | 15,901 |
| | RBNS | 73,893 | 73,302 | 591 |
| | ULAE | 20,682 | 0 | 20,682 |
| | **Subtotal** | **216,720** | **179,546** | **37,174** |
| **Total** | | **1,664,840** | **1,586,740** | **122,088** |

យោងតាមតារាងទី១ ពិនិត្យឃើញថា ប្រាក់បម្រុងហានិភ័យមិនទាន់ផុតសុពលភាពសុទ្ធ (Net Unexpired Risk Reserve) ចំនួន 76,855 ដុល្លារអាមេរិក ដែលភាគច្រើនរួមចំណែកមកពីការធានារ៉ាប់រងទ្រព្យសម្បត្តិ ការធានារ៉ាប់រងផ្សេងៗ និងការធានារ៉ាប់រងវិស្វកម្ម ។ ក្រុមហ៊ុន **អេស អិនសួរ៉ន ភីអិលស៊ី** មានប្រាក់បម្រុងហានិភ័យមិនទាន់ផុតសុពលភាពបន្ថែម (AURR) សរុបចំនួន 43,987 ដុល្លារអាមេរិក។ សម្រាប់ប្រាក់បម្រុងសំណងធានារ៉ាប់រងសុទ្ធ (Net Claim Liability) នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២៥ មានចំនួន 37,174 ដុល្លារអាមេរិក ដែលភាគច្រើនរួមចំណែកពីការធានារ៉ាប់រងទ្រព្យសម្បត្តិ និងការធានារ៉ាប់រងវិស្វកម្ម។ ប្រាក់បម្រុងសំណងធានារ៉ាប់រងសុទ្ធសម្រាប់ការធានារ៉ាប់រងទ្រព្យសម្បត្តិតំណាងឱ្យ 57% នៃបុព្វលាភធានារ៉ាប់រងបាត់ទុកជាចំណូលសុទ្ធសរុប (Net Earned Premium)។

## ៤) លទ្ធផលអំពីប្រតិបត្តិការអាជីវកម្ម

ក្នុងអំឡុងឆ្នាំរាយការណ៍ ក្រុមហ៊ុនបានបន្តអនុវត្តអាជីវកម្មធានារ៉ាប់រងស្របតាមផែនការអាជីវកម្ម និងគោលនយោបាយគ្រប់គ្រងហានិភ័យដែលបានកំណត់។ លទ្ធផលប្រតិបត្តិការអាជីវកម្មជារួមបង្ហាញពីការបន្តរីកចម្រើននៃសកម្មភាពអាជីវកម្ម និងការរក្សាបាននូវស្ថិរភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ចំណូលបុព្វលាភធានារ៉ាប់រងមានការកើនឡើងធៀបនឹងឆ្នាំមុន ដែលបង្ហាញពីការពង្រីកអាជីវកម្ម និងការបន្តទទួលបានការគាំទ្រពីអតិថិជន។ ក្រុមហ៊ុនបានបន្តពង្រឹងគុណភាពសេវាកម្ម និងការគ្រប់គ្រងផលប័ត្រធានារ៉ាប់រងប្រកបដោយប្រសិទ្ធភាព។

ក្នុងអំឡុងឆ្នាំរាយការណ៍ សំណងធានារ៉ាប់រងមានការកើនឡើងគួរឱ្យកត់សម្គាល់ បណ្តាលមកពីការកើនឡើងនៃការទាមទារសំណងពីអតិថិជន។ ទោះជាយ៉ាងណា ក្រុមហ៊ុននៅតែអនុវត្តការគ្រប់គ្រងសំណងដោយប្រុងប្រយ័ត្ន និងស្របតាមគោលការណ៍ និងនីតិវិធីដែលបានកំណត់។ ចំណាយប្រតិបត្តិការ និងចំណាយរដ្ឋបាលក៏មានការកើនឡើងស្របតាមការពង្រីកសកម្មភាពអាជីវកម្ម និងតម្រូវការគាំទ្រប្រតិបត្តិការរបស់ក្រុមហ៊ុន។

ដោយសារការកើនឡើងនៃសំណងធានារ៉ាប់រង និងចំណាយប្រតិបត្តិការ ប្រាក់ចំណេញរបស់ក្រុមហ៊ុនមានការថយចុះធៀបនឹងឆ្នាំមុន។ ទោះជាយ៉ាងណា ក្រុមហ៊ុននៅតែរក្សាបាននូវមូលដ្ឋានហិរញ្ញវត្ថុរឹងមាំ និងសមត្ថភាពក្នុងការបំពេញកាតព្វកិច្ចចំពោះអតិថិជន និងភាគីពាក់ព័ន្ធទាំងអស់។ ជារួម ក្រុមហ៊ុននឹងបន្តពង្រឹងការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងចំណាយ និងប្រសិទ្ធភាពប្រតិបត្តិការដើម្បីគាំទ្រដល់កំណើនអាជីវកម្មប្រកបដោយនិរន្តរភាពនាពេលអនាគត។

**បម្រែបម្រួលសំខាន់ៗនៃលទ្ធផលប្រតិបត្តិការអាជីវកម្ម**

១. ក្រុមហ៊ុនបានដាក់ឱ្យដំណើរការផលិតផលធានារ៉ាប់រងថ្មីៗ ដែលបានរួមចំណែកដល់ការពង្រីក និងបន្ថែមភាពសម្បូរបែបនៃផលិតផលធានារ៉ាប់រងរបស់ក្រុមហ៊ុន។

២. ចំណូលបុព្វលាភធានារ៉ាប់រងមានកំណើនគួរឱ្យកត់សម្គាល់ ដោយបុព្វលាភធានារ៉ាប់រងសរុបប្រចាំឆ្នាំបានកើនឡើងប្រមាណ ១៧% បើធៀបនឹងឆ្នាំ ២០២៤។

៣. ចំនួនករណីទាមទារសំណងដែលបានរាយការណ៍មានការកើនឡើង ប៉ុន្តែការដោះស្រាយ និងការទូទាត់សំណងសរុបនៅតែស្ថិតក្នុងកម្រិតសមស្រប និងស្ថានភាពប្រក្រតី។

៤. ក្រុមហ៊ុនបានអនុវត្តវិធានការគ្រប់គ្រងចំណាយប្រកបដោយប្រសិទ្ធភាព ដែលបានជួយលើកកម្ពស់កម្រិតនៃការគ្រប់គ្រងចំណាយ និងធ្វើឱ្យប្រសើរឡើងបើធៀបនឹងរយៈពេលមុន។

៥. ក្រៅពីបម្រែបម្រួលដែលបានរៀបរាប់ខាងលើ មិនមានបម្រែបម្រួលសំខាន់ ឬភាពមិនប្រក្រតីណាមួយនៅក្នុងផ្នែកប្រតិបត្តិការអាជីវកម្មផ្សេងៗរបស់ក្រុមហ៊ុនឡើយ។

## ៥) ការធានារ៉ាប់រងបន្ត

ក្រុមហ៊ុន អេស អិនស៊ូរិន ភីអិលស៊ី អនុម័តយុទ្ធសាស្ត្រធានារ៉ាប់រងបន្តដែលមានរចនាសម្ព័ន្ធ និងមានស្ថិរភាព ក្នុងគោលបំណងបែងចែក និងផ្ទេរហានិភ័យប្រកបដោយប្រសិទ្ធភាព ដើម្បីការពារមូលដ្ឋានដើមទុនរបស់ខ្លួន និងធានាបាននូវដំណើរការប្រតិបត្តិការដែលមានស្ថេរភាព។ ក្រុមហ៊ុនបានប្រើប្រាស់ការរៀបចំធានារ៉ាប់រងបន្ត ដើម្បីបង្កើនសមត្ថភាពធានារ៉ាប់រងរបស់ខ្លួន ដែលអាចឱ្យមានការរីកចម្រើនអាជីវកម្មប្រកបដោយចីរភាព ខណៈពេលដែលកម្រិតហានិភ័យនៅតែស្ថិតក្នុងកម្រិតកំណត់។ យុទ្ធសាស្ត្រនេះក៏គាំទ្រដល់ការរក្សាបាននូវកម្រិតសាធនភាពដ៏រឹងមាំ និងធានាបាននូវការអនុលោមយ៉ាងពេញលេញស្របតាមបទប្បញ្ញត្តិដែលអនុវត្តនៅក្នុងប្រទេសកម្ពុជា។

East Insurance Plc.

ក្រុមហ៊ុនប្រើប្រាស់រចនាសម្ព័ន្ធធានារ៉ាប់រងបន្តតាមការបែងចែកកូតាតាមសមាមាត្រ ដែលសមស្របទៅនឹងលក្ខណៈនៃខ្សែអាជីវកម្មនីមួយៗ ដោយធានាបាននូវតុល្យភាពសមស្របរវាងការរក្សាទុកហានិភ័យ និងការផ្ទេរហានិភ័យ។ ការរៀបចំទាំងអស់ត្រូវបានតម្រឹមស្របតាមបទប្បញ្ញត្តិក្នុងស្រុក និងតាមការអនុវត្តលើទីផ្សារអន្តរជាតិ។

ក្រុមហ៊ុនរក្សានូវស្តង់ដារយ៉ាងតឹងរឹងក្នុងការជ្រើសរើស និងគ្រប់គ្រងដៃគូធានារ៉ាប់រងបន្តដើម្បីធានាបាននូវសុវត្ថិភាព ស្ថេរភាព និងគុណភាពសេវាកម្មខ្ពស់។ ក្រុមហ៊ុនធានារ៉ាប់រងបន្តត្រូវបានជ្រើសរើសស្របតាមប្រកាសស្តីពីគោលការណ៍ស្តីពីការធានារ៉ាប់រងបន្តឆ្នាំ២០២៤ដែលកំណត់កម្រិតច្បាស់លាស់ក្នុងការផ្ទេរហានិភ័យដោយផ្អែកលើគុណភាពឥណទានរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្ត។ ក្រោមក្របខណ្ឌនេះ ក្រុមហ៊ុនធានារ៉ាប់រងបន្តចម្បងរបស់បរទេសដែលមានចំណាត់ថ្នាក់ខ្ពស់ ( ជាធម្មតា A- និងខ្ពស់ជាងនេះ ) អាចទទួលយកចំណែកធំនៃហានិភ័យ ដោយស្ថិតនៅក្រោមកម្រិតដែលបានកំណត់ ខណៈដែលក្រុមហ៊ុនធានារ៉ាប់រងបន្តដែលមានចំណាត់ថ្នាក់ទាបជាងត្រូវស្ថិតនៅក្រោមកម្រិតចូលរួមដែលមានការរឹតត្បិតជាង ។ វិធីសាស្ត្រនេះធានានូវតុល្យភាពសមស្របរវាងគុណភាពឥណទាន និងការចែកចាយហានិភ័យ ព្រមទាំងពង្រឹងក្របខណ្ឌគ្រប់គ្រងហានិភ័យរួមរបស់ក្រុមហ៊ុន។

## ហានិភ័យអតិបរមាដែលអនុញ្ញាតឱ្យផ្ទេរយោងតាមចំណាត់ថ្នាក់របស់ក្រុមហ៊ុនធានារ៉ាប់រងបន្ត

| ចំណាត់ថ្នាក់ឥណទាន ឬចំណាត់ថ្នាក់ឥណទានសមមូល | | | | កម្រិតអតិបរមានៃការផ្ទេរហានិភ័យក្នុងមួយកិច្ចព្រមព្រៀង |
|---|---|---|---|---|
| Standard & Poor | Moody | AM Best | Fitch | |
| AAA | Aaa | A++ | AAA | រហូតដល់ ៥០% សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងបន្តចំបងពីបរទេស; រហូតដល់ ១៥% សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងបន្តបរទេសដែលចូលរួមម្នាក់ៗ |
| AA+ | Aa1 | | AA+ | |
| AA | Aa2 | A+ | AA | |
| AA- | Aa3 | | AA- | |
| A+ | A1 | A | A+ | |
| A | A2 | A- | A | |
| A- | A3 | | A- | |
| BBB+ | Baa1 | B++ | BBB+ | រហូតដល់ ១០% សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងបន្តបរទេសដែលចូលរួមម្នាក់ៗ |
| BBB | Baa2 | B+ | BBB | |

លើសពីនេះ ក្រុមហ៊ុនធានារ៉ាប់រងបន្តត្រូវបានជ្រើសរើសដោយផ្អែកលើសំណុំស្តង់ដារគុណភាព និងបរិមាណ។ ក្រុមហ៊ុនសហការជាមួយតែក្រុមហ៊ុនធានារ៉ាប់រងបន្តដែលមានការអនុញ្ញាតត្រឹមត្រូវឱ្យធ្វើប្រតិបត្តិការ ឬដែលត្រូវបានទទួលស្គាល់ក្រោមស្តង់ដារបទប្បញ្ញត្តិ។ បន្ថែមពីនេះ ក្រុមហ៊ុនជ្រើសរើសក្រុមហ៊ុនធានារ៉ាប់រងបន្តដោយផ្តោតលើ ភាពរឹងមាំផ្នែកហិរញ្ញវត្ថុ និងចំណាត់ថ្នាក់ឥណទាន ក៏ដូចជា

ជំនាញបច្ចេកទេស និងបទពិសោធន៍ពាក់ព័ន្ធក្នុងការធានារ៉ាប់រងទូទៅ ជាពិសេសនៅក្នុងទីផ្សារកម្ពុជា និងតំបន់។

ក្រុមហ៊ុនក៏ធ្វើការវាយតម្លៃគ្រប់ជ្រុងជ្រោយឡើងវិញលើដៃគូធានារ៉ាប់រងបន្តទាំងអស់ យ៉ាងហោចណាស់រៀងរាល់បីឆ្នាំម្តង ដោយវាយតម្លៃកត្តានានា រួមមានភាពរឹងមាំផ្នែកហិរញ្ញវត្ថុ ការអនុលោមតាមបទប្បញ្ញត្តិ ការអនុវត្តសំណង គុណភាពសេវាកម្ម និងការតម្រឹមជាមួយយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន។ ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃនេះ ក្រុមហ៊ុនកែសម្រួលសមាសភាពក្រុមហ៊ុនធានារ៉ាប់រងបន្ត និងការបែងចែកអាជីវកម្មរបស់ខ្លួនតាមការចាំបាច់ ដើម្បីរក្សាការពារហានិភ័យឱ្យបានល្អបំផុត និងប្រសិទ្ធភាពអាជីវកម្ម។

ក្នុងអំឡុងពេលរបាយការណ៍ ការកែសម្រួលតិចតួចត្រូវបានធ្វើឡើងស្របតាមគោលការណ៍ណែនាំស្តីពីការធ្វើពិពិធកម្មធានារ៉ាប់រងបន្ត រួមទាំងការកែសម្រួលរចនាសម្ព័ន្ធនៃសមត្ថភាពធានារ៉ាប់រង និងលក្ខខណ្ឌនៃការដាក់ផ្ទេរហានិភ័យ។ ការផ្លាស់ប្តូរទាំងនេះមិនមានផលប៉ះពាល់ខ្លាំងទៅលើកម្រិតហានិភ័យរបស់ក្រុមហ៊ុន ឬកម្រិតនៃការការពារហានិភ័យនោះទេ។ ក្រុមហ៊ុននឹងបន្តតាមដានយ៉ាងជិតចំពោះការវិវត្តនៅក្នុងទីផ្សារធានារ៉ាប់រងបន្ត បច្ចុប្បន្នភាពនៃបទប្បញ្ញត្តិ និងស្ថានភាពហានិភ័យរបស់ខ្លួន ហើយនឹងធ្វើការកែសម្រួលចំពោះការរៀបចំធានារ៉ាប់រងបន្តរបស់ខ្លួនតាមការចាំបាច់ ដើម្បីធានាបាននូវប្រសិទ្ធភាព និងភាពធន់នឹងហានិភ័យប្រកបដោយចីរភាព។

## ៦) ការគ្រប់គ្រងហានិភ័យ

នៅឆ្នាំ ២០២៥ ក្រុមហ៊ុនបានបន្តពង្រឹងប្រព័ន្ធគ្រប់គ្រងហានិភ័យទូទាំងស្ថាប័ន ដោយអនុវត្តការកំណត់អត្តសញ្ញាណ វាយតម្លៃ តាមដាន និងគ្រប់គ្រងហានិភ័យប្រតិបត្តិកា សាច់ប្រាក់ងាយស្រួល ទីផ្សារធានារ៉ាប់រង និងហានិភ័យផ្សេងៗ។

ក្រុមហ៊ុនបានកែលម្អប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ពង្រឹងការគ្រប់គ្រងដៃគូអាជីវកម្ម និងអនុវត្តយ៉ាងតឹងរឹងនូវនីតិវិធីស្គាល់អតិថិជន (KYC) ចាប់ពីការផ្ទៀងផ្ទាត់អត្តសញ្ញាណ រហូតដល់ការត្រួតពិនិត្យជាបន្តបន្ទាប់។ ទន្ទឹមនឹងនេះ ក្រុមហ៊ុនបានគ្រប់គ្រងហានិភ័យទីផ្សារ ហានិភ័យសាច់ប្រាក់ងាយស្រួល និងហានិភ័យធានារ៉ាប់រងប្រកបដោយប្រសិទ្ធភាព។

ក្នុងអំឡុងរយៈពេលរាយការណ៍ មិនមានការផ្លាស់ប្តូរសំខាន់ណាមួយលើកត្តាហានិភ័យ និងប្រព័ន្ធគ្រប់គ្រងហានិភ័យឡើយ ហើយស្ថានភាពហានិភ័យសរុបរបស់ក្រុមហ៊ុននៅតែមានស្ថិរភាព និងអាចគ្រប់គ្រងបាន។

### ៧) ព័ត៌មានអំពីចីរភាព

ក្រុមហ៊ុនបានបន្តពង្រឹងយន្តការគ្រប់គ្រងការអភិវឌ្ឍប្រកបដោយចីរភាព ដោយបញ្ចូលការការពារបរិស្ថាន និងការទទួលខុសត្រូវសង្គមទៅក្នុងប្រតិបត្តិការប្រចាំថ្ងៃ។ ក្រុមហ៊ុនបានគ្រប់គ្រងយ៉ាងតឹងរឹងលើការប្រើប្រាស់ថាមពល និងការបញ្ចេញសារធាតុបំពុល ដើម្បីអនុវត្តប្រតិបត្តិការបៃតងចំពោះបរិស្ថាន។ ទន្ទឹមនឹងនេះ ក្រុមហ៊ុនបានអនុវត្តការគ្រប់គ្រងធនធានមនុស្សប្រកបដោយស្ថិរភាព ការពារ និងលើកកម្ពស់សិទ្ធិ និងផលប្រយោជន៍របស់បុគ្គលិក ព្រមទាំងសហការជាមួយដៃគូក្នុងខ្សែសង្វាក់អាជីវកម្ម ដើម្បីរួមគ្នាបំពេញទំនួលខុសត្រូវសង្គម និងជំរុញការអភិវឌ្ឍប្រកបដោយសមតុល្យរវាងបរិស្ថាន និងសង្គម។

## V. របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

លេខចុះបញ្ជីពាណិជ្ជកម្ម៖
០០០២៣៩១៧

# អេស អិនស្វិន ភីអិលស៊ី
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

# របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច និង
# របាយការណ៍របស់សវនករឯករាជ្យ
# ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

លេខចុះបញ្ជីពាណិជ្ជកម្ម៖
០០០២៣៩១៧

**អេស អិនស៊ូរិន ធីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

| **មាតិកា** | **ទំព័រ** |
|---|---|
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ១ - ៥ |
| របាយការណ៍របស់សវនកររងករាជ្យ | ៦ - ៩ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ១០ |
| របាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ | ១១ |
| របាយការណ៍បម្រែបម្រួលមូលធន | ១២ |
| របាយការណ៍លំហូរសាច់ប្រាក់ | ១៣ |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | ១៤ - ៣៦ |

លេខចុះបញ្ជីពាណិជ្ជកម្ម៖
០០០២៣៩១៧

**អេស អិនសូរិន ភីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**ព័ត៌មានអំពីក្រុមហ៊ុន**

| | |
|---|---|
| ក្រុមប្រឹក្សាភិបាល៖ | Tan Wen Chao<br>Wang Jun Feng<br>Zhang Fen<br>Qi Xin Bin<br>Mao Chengen<br>ស៊ុយ សុខរស្មី<br>Li Xi |
| ទីស្នាក់ការ៖ | អគារលេខ ១៨២ មហាវិថីព្រះសីហនុ<br>សង្កាត់បឹងកេងកង១ ខណ្ឌចំការមន<br>រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា |
| ធនាគារ៖ | ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី<br>ធនាគារ ភ្នំពេញពាណិជ្ជ ម.ក<br>ធនាគារ កាណាឌីយ៉ា ក.អ<br>ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក<br>ធនាគារ ភីក វេល ម.ក<br>ធនាគារ អូរៀនថល<br>ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់<br>ធនាគារ អ៊ឹមប៊ី (ខេមបូឌា) ម.ក |
| សវនករ៖ | ហ្រ្គេន សនថុន (ខេមបូឌា) លីមីធីត |

**អេស អិនស៊ូរិន ភីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានសេចក្តីសោមនស្សរីករាយក្នុងការដាក់ជូននូវរបាយការណ៍ ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច របស់ អេស អិនស៊ូរិន ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។

### សកម្មភាពអាជីវកម្មចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មធានារ៉ាប់រងទូទៅនៅកម្ពុជា។ ពុំមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៃលក្ខណៈសកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុនក្នុងអំឡុងការិយបរិច្ឆេទនេះទេ។

### លទ្ធផលនៃប្រតិបត្តិការ

| | ដុល្លារអាមេរិក | ពាន់រៀល |
|---|---|---|
| ចំណេញសម្រាប់ការិយបរិច្ឆេទ | ១៦២.៤២៥ | ៥៥៦.២៨១ |

### ភាគលាភ

ក្រុមប្រឹក្សាភិបាលពុំបានផ្តល់អនុសាសន៍ឱ្យមានការទូទាត់ភាគលាភណាមួយសម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ននេះទេ។

### ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅ ឬពីទុនបម្រុង ឬសំវិធានធនក្នុងអំឡុងការិយបរិច្ឆេទបច្ចុប្បន្ននេះទេ។

### បំណុលអាក្រក់ និងបំណុលជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ហើយក្រុមប្រឹក្សាភិបាល បានចាត់វិធានការដែលមានមូលដ្ឋានសមស្រប ដើម្បីបញ្ជាក់ថា វិធានការដែលទាក់ទងទៅនឹងការលុបចោលបំណុលអាក្រក់ និងមានការធ្វើសំវិធានធនសម្រាប់បំណុលជាប់សង្ស័យ ត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាល មានការជឿជាក់ថា ពុំមានបំណុលអាក្រក់ ហើយសំវិធានធនត្រូវបានធ្វើឡើងគ្រប់គ្រាន់សម្រាប់បំណុលជាប់សង្ស័យ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងបណ្តាលឱ្យមានភាពចាំបាច់ ដើម្បីលុបចោលនូវបំណុលអាក្រក់ ឬផ្តល់សំវិធានធនសម្រាប់បំណុលជាប់សង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននេះឡើយ។

### ទ្រព្យសកម្មរយៈពេលខ្លី

នៅមុនពេលដែលរបាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាល បានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មរយៈពេលខ្លីដែលមិនមានតម្លៃស្មើនឹងតម្លៃទីផ្សារ នៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានកាត់បន្ថយតម្លៃឱ្យនៅត្រឹមតម្លៃដែលរំពឹងទុកនឹងអាចលក់បានលើទីផ្សារ។

**អេស អិនសុរិន គីអិលស៊ី**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល(ត)**

**ទ្រព្យសកម្មរយៈពេលខ្លី (ត)**

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងបណ្តាលឱ្យមានការភាន់ច្រឡំដល់ការកំណត់តម្លៃទ្រព្យសកម្មរយៈពេលខ្លីនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

**វិធីសាស្ត្រកំណត់តម្លៃ**

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង និងដែលអាចបណ្តាលឱ្យមានការភាន់ច្រឡំ ឬមានភាពមិនត្រឹមត្រូវដល់វិធីសាស្ត្រកំណត់តម្លៃ ដែលបានអនុវត្តកន្លងមកលើទ្រព្យសកម្ម និងបំណុលរបស់ក្រុមហ៊ុនឡើយ។

**បំណុលយថាហេតុ និងបំណុលផ្សេងៗ**

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(១) បន្ទុកណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលបានកើតឡើង ដោយសារការដាក់បញ្ចាំសម្រាប់ធានា បំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីចុងការិយបរិច្ឆេទនេះ ឬ

(២) បំណុលយថាហេតុណាមួយរបស់ក្រុមហ៊ុនដែលបានកើតឡើងចាប់តាំងពីចុងការិយបរិច្ឆេទនេះ។

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗដែលត្រូវបានទាមទារឱ្យសង ឬអាចត្រូវបានទាមទារឱ្យសងក្នុងអំឡុងពេល ១២ខែ បន្ទាប់ពីចុងការិយបរិច្ឆេទនេះ ដែលនឹងអាចមានផលប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចសងបំណុលរបស់ខ្លួននៅថ្ងៃកំណត់សងនោះទេ។

**ការផ្លាស់ប្តូរនៃហេតុការណ៍**

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនត្រូវបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលបណ្តាលឱ្យសមតុល្យ ដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានការភាន់ច្រឡំនោះឡើយ។

**ប្រតិបត្តិការមិនប្រក្រតី**

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន ក្នុងអំឡុងការិយបរិច្ឆេទនេះ មិនបានទទួលរងនូវឥទ្ធិពលធ្ងន់ធ្ងរ ដែលកើតចេញពីកត្តាផ្សេងៗ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ទាំងឡាយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះឡើយ។

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះនៃចុងការិយបរិច្ឆេទរហូតដល់កាលបរិច្ឆេទនៃការចេញរបាយការណ៍នេះ ពុំមានខ្ទង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ដែលមានលក្ខណៈជាសារវន្ត ឬមិនប្រក្រតីណាមួយបានកើតឡើង ដែលអាចឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធផលអាជីវកម្មរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទ ដែលរបាយការណ៍ត្រូវបានធ្វើឡើងនោះឡើយ។

# អេស អិនសុរិន អីអិលស៊ី
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

### ដើមទុន

ក្រុមហ៊ុន មានវិភាគទានដើមទុនបន្ថែមក្នុងសមតុល្យ ២៥០.០០០ ដុល្លារអាមេរិកនៅក្នុងអំឡុងការិយបរិច្ឆេទនេះទេ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ដើមទុនរបស់ក្រុមហ៊ុនមានសមតុល្យ ៨.២៥០.០០០ ដុល្លារអាមេរិក (ឆ្នាំ២០២៤៖ ៨.០០០.០០០ ដុល្លារអាមេរិក)។

ក្រុមហ៊ុនពុំមានកិច្ចសន្យាផ្តល់ភាគហ៊ុនមិនទាន់បោះផ្សាយ និងមិនមានភាគហ៊ុនក្រោមកិច្ចសន្យាផ្តល់សិទ្ធិជាភាគហ៊ុនរបស់ក្រុមហ៊ុននាចុងការិយបរិច្ឆេទនេះទេ។

### ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ដែលនៅបម្រើការចាប់តាំងពីកាលបរិច្ឆេទនៃរបាយការណ៍ចុងក្រោយនេះមាន៖

Tan Wen Chao
Wang Jun Feng
Zhang Fen
Qi Xin Bin
Mao Chengen
ស៊ុយ សុខរស្មី
Li Xi

### អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាលនៅក្នុងក្រុមហ៊ុន

ក្នុងអំឡុង និងចុងការិយបរិច្ឆេទនេះ ពុំមានការរៀបចំណាមួយ ដែលមានក្រុមហ៊ុនជាភាគីមួយ ក្នុងគោលបំណងជួយដល់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយការទិញយកភាគហ៊ុន ឬបណ្ណបំណុលរបស់ក្រុមហ៊ុន ឬពីក្រុមហ៊ុនសាជីវកម្មផ្សេងៗទៀតឡើយ។

ចាប់តាំងពីចុងការិយបរិច្ឆេទមុនៗ ក្រុមប្រឹក្សាភិបាល ពុំបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ តាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើងដោយក្រុមហ៊ុន ឬដោយក្រុមហ៊ុនសាជីវកម្មដែលពាក់ព័ន្ធណាមួយជាមួយនឹងក្រុមប្រឹក្សាភិបាល ឬជាមួយក្រុមហ៊ុនដែលមានអភិបាលជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាល មានអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តឡើយ។

**អេស អិនសុរិន តីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)**

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានទំនួលខុសត្រូវក្នុងការបញ្ជាក់អះអាងថា របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំឡើង ត្រូវបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាគណនេយ្យនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។ ក្រុមប្រឹក្សាភិបាល ជាអ្នកត្រួតពិនិត្យជារួមនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំឡើងដោយគណៈគ្រប់គ្រងហើយតម្រូវឱ្យ៖

(ក) អនុវត្តគោលនយោបាយគណនេយ្យសមស្របដោយអនុលោមតាមស្តង់ដាគណនេយ្យនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ដែលគាំទ្រដោយសមហេតុផល និងផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានប្រកបដោយភាពហ្មត់ចត់ និងប្រុងប្រយ័ត្ន ហើយអនុវត្តគោលនយោបាយទាំងនេះឱ្យមានសង្គតិភាព

(ខ) អនុលោមតាមគោលការណ៍ដែលតម្រូវដោយស្តង់ដាគណនេយ្យនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយដែលតម្រូវឱ្យមាននៃស្តង់ដានេះ ក្នុងការបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ ត្រូវប្រាកដថា ការប្រាសចាកទាំងនេះ ត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(គ) រក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងមានប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព ដែលអាចឱ្យក្រុមហ៊ុនរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលអនុលោមតាមស្តង់ដាគណនេយ្យនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនសមរម្យក្នុងការសន្មតថា ក្រុមហ៊ុននឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគតដែលអាចប៉ាន់ស្មានបាន និង

(ង) ត្រួតពិនិត្យ និងដឹកនាំ ក្រុមហ៊ុនឱ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចចិត្តជាសារវន្ត ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថា សេចក្តីសម្រេចចិត្តទាំងនេះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមរាល់តម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

គណៈគ្រប់គ្រង គឺទទួលខុសត្រូវក្នុងការធានាថា កំណត់ត្រាគណនេយ្យមានភាពត្រឹមត្រូវ ហើយត្រូវបានរក្សាទុកដូចដែលបានលាតត្រដាងដោយបង្ហាញនូវភាពត្រឹមត្រូវ សមហេតុផលគ្រប់ពេលវេលាពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងដើម្បីធានាថាការកត់ត្រាគណនេយ្យអនុលោមតាមការអនុវត្តនៃប្រព័ន្ធគណនេយ្យ។ គណៈគ្រប់គ្រង ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ហើយក៏ត្រូវចាត់វិធានការឱ្យសមស្របដើម្បីទប់ស្កាត់ និងរកឱ្យឃើញការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

លេខចុះបញ្ជីពាណិជ្ជកម្ម៖
០០០២៣៩១៧



**អេស អិនស៊ូរិន ភីអិលស៊ី**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)**

គណៈគ្រប់គ្រង សូមបញ្ជាក់ថា ក្រុមហ៊ុនបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នានា ដូចដែលបានបញ្ជាក់ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ។

**ការអនុម័តទៅលើរបាយការណ៍ហិរញ្ញវត្ថុ**

យើងខ្ញុំយល់ព្រមអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលអមមកជាមួយនេះ ដែលផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាគណនេយ្យនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

ចុះហត្ថលេខាតំណាងឱ្យក្រុមប្រឹក្សាភិបាលដោយអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន អេស អិនស៊ូរិន ភីអិលស៊ី EAST INSURANCE PLC. KINGDOM OF CAMBODIA

**លោក Tan Wen Chao**
ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦

Grant Thornton

**ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត**
ជាន់ទី២០ អគារកាណាឌីយ៉ា
៣១៥ ផ្លូវព្រះអង្គឌួង
(កែងមហាវិថីព្រះមុនីវង្ស)
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
លេខទូរស័ព្ទ +៨៥៥ ២៣ ៩៦៦ ៥២០

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះភាគហ៊ុនិករបស់
## អេស អិនសូរិន ភីអិលស៊ី

## មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ អេស អិនសូរិន ភីអិលស៊ី (ហៅកាត់ថា "ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងរបាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត និងសេចក្តីពន្យល់ព័ត៌មានផ្សេងៗ។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាគណនេយ្យនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ដូចដែលបានអនុវត្តដោយនិយ័តករគណនេយ្យ និងសវនកម្មនៃកម្ពុជា ដោយផ្អែកទៅលើស្តង់ដាគណនេយ្យនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដូចដែលបានអនុម័តដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ។

## មូលដ្ឋាននៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា ("CISAs")។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដាទាំងនោះ គឺត្រូវបានរៀបរាប់បន្ថែមនៅក្នុងផ្នែកការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានឯករាជ្យភាពពីក្រុមហ៊ុនដោយអនុលោមតាមក្រុមប្រឹក្សាស្តង់ដាវិជ្ជាជីវៈគណនេយ្យអន្តរជាតិ ក្រមសីលធម៌របស់គណនេយ្យករជំនាញ (រួមទាំងស្តង់ដាឯករាជ្យអន្តរជាតិ) ("IESBA Code") រួមជាមួយនឹងតម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំបានបំពេញការទទួលខុសត្រូវទៅតាមតម្រូវការក្រមសីលធម៌ទាំងនោះ និង IESBA Code។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្ម ដែលយើងខ្ញុំទទួលបានគឺគ្រប់គ្រាន់ និងសមស្រប ដើម្បីធ្វើជាមូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។



**គណនេយ្យករជំនាញ និងសវនករប្រតិស្រុត**
ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត គឺជាសមាជិករបស់ក្រុមហ៊ុនហ្គ្រេន សនថុន អន្តរជាតិ (ហ្គ្រេន សនថុន អន្តរជាតិ)។ ហ្គ្រេន សនថុន គឺសំដៅដល់ឈ្មោះដែលសមាជិករបស់ក្រុមហ៊ុនហ្គ្រេន សនថុនធ្វើប្រតិបត្តិការ និងសំដៅដល់ក្រុមហ៊ុនមួយ ឬក្រុមហ៊ុនជាសមាជិកច្រើន តាមបរិបទតម្រូវ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិកមិនមែនជាដៃគូពាណិជ្ជកម្មទូទាំងសកលលោកទេ។ រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ ហើយសេវាកម្ម ឬសកម្មភាពនៃសមាជិកនីមួយៗមិនមែនជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនហ្គ្រេន សនថុនផ្សេងទៀតទេ។

grantthornton.com.kh

**Grant Thornton**

## ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រង មានទំនួលខុសត្រូវទាំងស្រុងទៅលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗទាំងនោះរួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរបាយការណ៍សវនកម្មរបស់យើងខ្ញុំឡើយ។

មតិយោបល់របស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗទេ ហើយយើងខ្ញុំក៏មិនផ្តល់សេចក្តីសន្និដ្ឋានក្នុងទម្រង់នៃការធានាបែបណាមួយឡើយ។

ភ្ជាប់ជាមួយការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន យើងខ្ញុំមានទំនួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានវិសមភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុឬទេ ឬចំណេះដឹងរបស់យើងខ្ញុំដែលទទួលបានពីការធ្វើសវនកម្មថាតើព័ត៌មានទាំងនោះអាចមានកំហុសឆ្គងជាសារវន្តឬទេ។

ប្រសិនបើផ្អែកតាមការងារដែលយើងខ្ញុំធ្វើសវនកម្ម យើងខ្ញុំសន្និដ្ឋានថាមានកំហុសជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍នៅក្នុងករណីនេះឡើយ។

## បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹម និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ត្រូវបានសវនកម្មដោយសវនករផ្សេងទៀត ដែលបានបង្ហាញមតិយោបល់ត្រឹមត្រូវទៅលើរបាយការណ៍ហិរញ្ញវត្ថុទាំងនោះនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលទៅលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងរបស់ក្រុមហ៊ុនទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ឱ្យបានត្រឹមត្រូវដោយអនុលោមទៅតាមស្តង់ដាគណនេយ្យនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថា វាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឱ្យមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រង មានទំនួលខុសត្រូវចំពោះការវាយតម្លៃទៅលើសមត្ថភាពក្រុមហ៊ុនក្នុងការបន្តប្រតិបត្តិការដោយផ្អែកលើមូលដ្ឋានបន្តនិរន្តរភាព ការលាតត្រដាង ប្រសិនជាមានបញ្ហាទាក់ទងនឹងការបន្តនិរន្តរភាព និងការប្រើប្រាស់និរន្តរភាពជាមូលដ្ឋានគណនេយ្យ លុះត្រាតែគណៈគ្រប់គ្រង មានគោលបំណងរំសាយក្រុមហ៊ុន ឬបញ្ឈប់ ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេង ប៉ុន្តែចាំបាច់ត្រូវធ្វើ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យលើដំណើរការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។



**គណនេយ្យករជំនាញ និងសវនករប្រតិស្រុត**
ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត គឺជាសមាជិករបស់ក្រុមហ៊ុនហ្គ្រេន សនថុន អន្តរជាតិ (ហ្គ្រេន សនថុន អន្តរជាតិ)។ ហ្គ្រេន សនថុន គឺសំដៅដល់ឈ្មោះដែលសមាជិករបស់ក្រុមហ៊ុនហ្គ្រេន សនថុនធ្វើប្រតិបត្តិការ និងសំដៅដល់ក្រុមហ៊ុនមួយ ឬក្រុមហ៊ុនជាសមាជិកច្រើន តាមបរិបទតម្រូវ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិកមិនមែនជាដៃគូពាណិជ្ជកម្មទូទាំងសកលលោកទេ។ រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ ហើយសេវាកម្ម ឬសកម្មភាពនៃសមាជិកនីមួយៗមិនមែនជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនហ្គ្រេន សនថុនផ្សេងទៀតទេ។

grantthornton.com.kh

Grant Thornton

## ការទទួលខុសត្រូវរបស់សវនករនៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផល ទៅលើរបាយការណ៍ហិរញ្ញវត្ថុដោយពុំមានលក្ខណៈខុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង និងការចេញរបាយការណ៍សវនករដែលរួមមានមតិយោបល់របស់យើងខ្ញុំផងដែរ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាដែលមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនបានធានាថាការធ្វើសវនកម្មដោយផ្អែកទៅលើស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជានឹងតែងតែរកឃើញនូវការរាយការណ៍ខុសជាសារវន្តដែលកើតមានឡើងនោះឡើយ។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើ ឱ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយយោងទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យ និងរក្សាមជ្ឈធាតុនិយមប្រកបដោយវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏បាន៖

- កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យនៃការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ថាតើវាកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គងដោយអចេតនា រៀបចំនិងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្រប ដើម្បីជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គងដោយអចេតនាដោយសារតែការក្លែងបន្លំ រួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនា ការលុបចោលដោយចេតនា ការធ្វើបទបង្ហាញមិនអស់សេចក្តី ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង។

- ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុងដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនីតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។

- ធ្វើការវាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន ក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយគណៈគ្រប់គ្រង។

វិធីសាស្ត្រដែលប្រើក្នុងការគណនាបុព្វលាភបម្រុងនេះ គឺវិធីសាស្ត្រ ១/៣៦៥ ដែលបែងចែកជាប្រាក់ចំណូលបុព្វលាភតាមមូលដ្ឋានប្រចាំថ្ងៃក្នុងរយៈពេលតាមគោលនយោបាយ។

គណៈគ្រប់គ្រងបានអនុវត្តក្នុងការធ្វើតេស្តគ្រប់គ្រាន់លើបំណុលគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ហើយពុំមានភាពខ្វះខាតដែលបានរកឃើញឡើយ។

(គ) បំណុលកិច្ចសន្យាធានារ៉ាប់រងត្រូវបានចារឹកតម្លៃជាប្រាក់ដុល្លារអាមេរិក។

## ១២. គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ភាគីទីបី | **៩៣០.០៣៥** | **៣.៧៣២.២៣០** | ៧០៨.៤២១ | ២.៨៥១.៣៩៥ |
| គណនីត្រូវសងផ្សេងៗ | **១៣.៦៤៦** | **៥៤.៧៦១** | ៨.៥០០ | ៣៤.២១២ |
| | **៩៤៣.៦៨១** | **៣.៧៨៦.៩៩១** | ៧១៦.៩២១ | ២.៨៨៥.៦០៧ |

(ក) គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ ត្រូវបានធ្វើចំណាត់ថ្នាក់ជាបំណុលហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់។

(ខ) គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ ត្រូវបានចារឹកតម្លៃជាប្រាក់ដុល្លារអាមេរិក។

(គ) ទម្រង់កាលកំណត់នៃគណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗរបស់ក្រុមហ៊ុននៅចុងការិយបរិច្ឆេទនៃការរាយការណ៍ គឺផ្អែកលើកាតព្វកិច្ចទូទាត់សងដែលមិនមានអប្បហារដែលបានចុះកិច្ចសន្យា គឺអាចត្រូវសងតាមតម្រូវការ ឬក្នុងរយៈពេលមួយឆ្នាំ។

## ១៣. បុព្វលាភសុទ្ធ

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលបុព្វលាភដុល | | | | |
| កិច្ចសន្យាធានារ៉ាប់រង | **៤.១៨១.០៨២** | **១៦.៧៧០.៣២០** | ២.៤៥៥.២៤៦ | ៩.៩៩៥.៣០៦ |
| បម្រែបម្រួលសំវិធានធននៃបុព្វលាភ មិនទាន់ទទួលស្គាល់ | **(១.៨០៣.៤២៥)** | **(៧.២៣៣.៥៣៨)** | (១.០៦១.៩៣៤) | (៤.៣២៣.១៣៣) |
| | **២.៣៧៧.៦៥៧** | **៩.៥៣៦.៧៨២** | ១.៣៩៣.៣១២ | ៥.៦៧២.១៧៣ |
| បុព្វលាភអនុប្បទាធានារ៉ាប់រងបន្ត | | | | |
| កិច្ចសន្យាធានារ៉ាប់រង | **៣.៨០៤.៤១៣** | **១៥.២៥៩.៥០០** | ២.៣២២.០០៣ | ៩.៤៥២.៨៧៤ |
| បម្រែបម្រួលសំវិធានធននៃបុព្វលាភ មិនទាន់ទទួលស្គាល់ | **(១.៦៨៥.៦៤៣)** | **(៦.៧៦១.១១៤)** | (៩៦៧.៨៩៥) | (៣.៩៤០.៣០០) |
| | **២.១១៨.៧៧០** | **៨.៤៩៨.៣៨៦** | ១.៣៥៤.១០៨ | ៥.៥១២.៥៧៤ |
| ចំណូលបុព្វលាភសុទ្ធ | ***២៥៨.៨៨៧*** | ***១.០៣៨.៣៩៦*** | *៣៩.២០៤* | *១៥៩.៥៩៩* |

## ១៣. បុព្វលាភសុទ្ធ (ត)

(ក) ចំណូលបុព្វលាភ

ចំណូលបុព្វលាភ ត្រូវបានទទួលស្គាល់ជាចំណូលនៅក្នុងការិយបរិច្ឆេទទៅតាមហានិភ័យ ដែលបានសន្មតនៅក្នុងការិយបរិច្ឆេទជាក់លាក់។

(ខ) ធានារ៉ាប់រងបន្ត

បុព្វលាភធានារ៉ាប់រងបន្ត ត្រូវបានទទួលស្គាល់ស្របតាមសន្និសញ្ញានៃកិច្ចសន្យាធានារ៉ាប់រងបន្ត ពេលទទួលបានលិខិតបញ្ជាក់ពីក្រុមប្រឹក្សាធានារ៉ាប់រងបន្ត និងក្នុងលក្ខណៈមួយដែលស្របជាមួយនឹងការវាស់វែងតាមមូលដ្ឋានកិច្ចសន្យាធានារ៉ាប់រង។

(គ) លទ្ធផលការធានាតាមផ្នែក

| | យានយន្ត<br>ដុល្លារអាមេរិក | ទោចក្រ-<br>យានយន្ត<br>ដុល្លារអាមេរិក | គ្រោះថ្នាក់បុគ្គល<br>ដុល្លារអាមេរិក | អគ្គីភ័យ<br>ដុល្លារអាមេរិក | សុខភាព<br>ដុល្លារអាមេរិក | អចលនទ្រព្យ និង<br>ការខូចខាតនៃម៉ាស៊ីន<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|
| **២០២៥** | | | | | | | |
| **ចំណូលបុព្វលាភដុល** | | | | | | | |
| **កិច្ចសន្យាធានារ៉ាប់រង** | **៥៦០.៦១០** | **៧០៨.៥៤៩** | **៥២.៧១៦** | **១២៣.៦៦៤** | **៦៦២.៦០៤** | **២.០៧២.៩៣៩** | **៤.១៨១.០៨២** |
| **បម្រែបម្រួលសំវិធានធននៃបុព្វលាភមិនទាន់ទទួលបាន** | **(១១.៧៦៦)** | **(៤៧៩.៩៩៥)** | **(១៧.៩៩៣)** | **(៣៦.៩៦៦)** | **(៣៧៣.៦១៦)** | **(៨៨៣.០៨៩)** | **(១.៨០៣.៤២៥)** |
| | **៥៤៨.៨៤៤** | **២២៨.៥៥៤** | **៣៤.៧២៣** | **៨៦.៦៩៨** | **២៨៨.៩៨៨** | **១.១៨៩.៨៥០** | **២.៣៧៧.៦៥៧** |
| **បុព្វលាភអនុប្បទានធានារ៉ាប់រងបន្ត** | | | | | | | |
| កិច្ចសន្យាធានារ៉ាប់រង | ៤៧៧.៣៧១ | ៧០០.១១០ | ២៦.៧៣៤ | ៥៣.១០១ | ៦៥០.៧៥០ | ១.៨៩៦.៣៤៧ | ៣.៨០៤.៤១៣ |
| បម្រែបម្រួលសំវិធានធននៃបុព្វលាភមិនទាន់ទទួលបាន | (៣.៥២៩) | (៤៧៩.៩៩៥) | (១០.៨០៤) | (១៥.៩១៦) | (៣៧២.៧៨៦) | (៨០២.៦១៣) | (១.៦៨៥.៦៤៣) |
| | **៤៧៣.៨៤២** | **២២០.១១៥** | **១៥.៩៣០** | **៣៧.១៨៥** | **២៧៧.៩៦៤** | **១.០៩៣.៧៣៤** | **២.១១៨.៧៧០** |
| **ចំណូលបុព្វលាភសុទ្ធ** | **៧៥.០០២** | **៨.៤៣៩** | **១៨.៧៩៣** | **៤៩.៥១៣** | **១១.០២៤** | **៩៦.១១៦** | **២៥៨.៨៨៧** |
| *(សមមូលគិតជាពាន់រៀល)* | ***៣០០.៨៣៣*** | ***៣៣.៨៤៩*** | ***៧៥.៣៧៩*** | ***១៩៨.៥៩៧*** | ***៤៤.២១៧*** | ***៣៨៥.៥២១*** | ***១.០៣៨.៣៩៦*** |

## ១៣. **បុព្វលាភសុទ្ធ (ត)**

(គ) លទ្ធផលការធានាតាមផ្នែក (ត)

| | យានយន្ត<br>ដុល្លារអាមេរិក | ទោចក្រ-<br>យានយន្ត<br>ដុល្លារអាមេរិក | គ្រោះថ្នាក់បុគ្គល<br>ដុល្លារអាមេរិក | អគ្គីភ័យ<br>ដុល្លារអាមេរិក | សុខភាព<br>ដុល្លារអាមេរិក | អចលនទ្រព្យ និង<br>ការខូចខាតនម៉ាស៊ីន<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|
| ២០២៤ | | | | | | | |
| ចំណូលបុព្វលាភដុល | | | | | | | |
| កិច្ចសន្យាធានារ៉ាប់រង | ៦៥១.០៣៨ | ៣៦.១៩០ | ៧៤.៣៥៣ | ១៣០.០៥៦ | ៣៩.១២១ | ១.៥២៤.៤៨៨ | ២.៤៥៥.២៤៦ |
| បម្រែបម្រួលសំវិធានធននៃបុព្វលាភមិនទាន់ទទួលបាន | (៥៣៤.៧៧៧) | (១០.៥៤៩) | (២៥.៤៨៧) | (៤២.៤៦៤) | (១០.៦៤២) | (៤៣៨.០១៥) | (១.០៦១.៩៣៤) |
| | ១១៦.២៦១ | ២៥.៦៤១ | ៤៨.៨៦៦ | ៨៧.៥៩២ | ២៨.៤៧៩ | ១.០៨៦.៤៧៣ | ១.៣៩៣.៣១២ |
| បុព្វលាភអនុប្បទាធានារ៉ាប់រងបន្ត | | | | | | | |
| កិច្ចសន្យាធានារ៉ាប់រង | ៥៥៦.៣៩៩ | ៧.២៣៨ | ២៣.១៩២ | ៥០.៨១៨ | ២៦.៩៧៧ | ១.៦៥៧.៣៧៩ | ២.៣២២.០០៣ |
| បម្រែបម្រួលសំវិធានធននៃបុព្វលាភមិនទាន់ទទួលស្គាល់ | (៤៦៩.៦២១) | (២.១១០) | (១១.២៣០) | (៩.០៣៨) | (២.១២៨) | (៤៧៣.៧៦៨) | (៩៦៧.៨៩៥) |
| | ៨៦.៧៧៨ | ៥.១២៨ | ១១.៩៦២ | ៤១.៧៨០ | ២៤.៨៤៩ | ១.១៨៣.៦១១ | ១.៣៥៤.១០៨ |
| ចំណូលបុព្វលាភសុទ្ធ | ២៩.៤៨៣ | ២០.៥១៣ | ៣៦.៩០៤ | ៤៥.៨១២ | ៣.៦៣០ | (៩៧.១៣៨) | ៣៩.២០៤ |
| *(សមមូលគិតជាពាន់រៀល)* | *១២០.០២៥* | *៨៣.៥០៨* | *១៥០.២៣៦* | *១៨៦.៥០១* | *១៤.៧៧៨* | *(៣៩៥.៤៤៩)* | *១៥៩.៥៩៩* |

## ១៤. ចំណូលផ្សេងៗ

| | ២០២៥ ដុល្លារអាមេរិក | ២០២៥ ពាន់រៀល | ២០២៤ ដុល្លារអាមេរិក | ២០២៤ ពាន់រៀល |
|---|---|---|---|---|
| ចំណូលការប្រាក់ | **៣០៤.៣២៥** | **១.២២០.៦៤៨** | ២៩០.៨៨៣ | ១.១៨៤.១៨៥ |
| កម្រៃជើងសា | **៣១៦.៧៨៤** | **១.២៧០.៦២១** | ២២៥.៥៦៨ | ៩១៨.២៨៧ |
| ផ្សេងៗ | **៩.៩២៣** | **៣៩.៨០០** | - | - |
| | **៦៣១.០៣២** | **២.៥៣១.០៦៩** | ៥១៦.៤៥១ | ២.១០២.៤៧២ |

(ក) ចំណូលការប្រាក់

ចំណូលការប្រាក់ ត្រូវបានទទួលស្គាល់ជាការបង្គរដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

(ខ) កម្រៃជើងសា

ចំណូលពីកម្រៃជើងសា ត្រូវបានកត់ត្រានៅពេលដែលសិទ្ធិទទួលបានការទូទាត់ត្រូវបានបង្កើតឡើង។

## ១៥. បម្រែបម្រួលជុលនៃចំណុលកិច្ចសន្យា

| | ២០២៥ ដុល្លារអាមេរិក | ២០២៥ ពាន់រៀល | ២០២៤ ដុល្លារអាមេរិក | ២០២៤ ពាន់រៀល |
|---|---|---|---|---|
| កិច្ចសន្យាធានារ៉ាប់រង | **(២៧.២២៧)** | **(១០៩.២០៧)** | ៥៩.៣៩១ | ២៤១.៧៨១ |

## ១៦. ចំណាយរដ្ឋបាល

| | ២០២៥ ដុល្លារអាមេរិក | ២០២៥ ពាន់រៀល | ២០២៤ ដុល្លារអាមេរិក | ២០២៤ ពាន់រៀល |
|---|---|---|---|---|
| ចំណាយទៅលើបុគ្គលិក | **២៦១.៣៨០** | **១.០៤៨.៣៩៥** | ១៦៣.៥៤៦ | ៦៦៥.៧៩៦ |
| សំណងដែលបានបង់ | **១៩៣.៨៧៧** | **៧៧៧.៦៤១** | ៣២.៨៤៨ | ១៣៣.៧២៤ |
| រំលស់សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម | **៤០.៦៤១** | **១៦៣.០១១** | ១១.១៤២ | ៤៥.៣៥៩ |
| ចំណាយពន្ធផ្សេងៗ | **២១.៨៩២** | **៨៧.៨០៩** | ២៤.៤៩១ | ៩៩.៧០៣ |
| កម្រៃសេវាវិជ្ជាជីវៈ | **២១.៦៨៩** | **៨៦.៩៩៥** | ១៥.៦៣៩ | ៦៣.៦៦៦ |
| ការិយាល័យ និងសម្ភារការិយាល័យ | **៤.៤៤៤** | **១៧.៨២៥** | ២.៩៣៤ | ១១.៩៤៤ |
| សេវាធនាគារ | **៣.២៣៩** | **១២.៩៩២** | ២.៨៣៣ | ១១.៥៣៣ |
| ការជួល | - | - | ៣៣៧ | ១.៣៧២ |
| ចំណាយផ្សេងៗ | **៣៦.៩១៧** | **១៤៨.០៧៣** | ៣៧.២៤៩ | ១៥១.៦៤១ |
| | **៥៨៤.០៧៩** | **២.៣៤២.៧៤១** | ២៩១.០១៩ | ១.១៨៤.៧៣៨ |

## ១៧. ចំណាយហិរញ្ញវត្ថុ

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណាយការប្រាក់លើបំណុលភតិសន្យា | **៥.៦៧៣** | **២២.៧៥៤** | ២.០៨៩ | ៨.៥០៤ |

## ១៨. ចំណាយពន្ធ

(ក) ចំណាយពន្ធលើប្រាក់ចំណូល

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណាយពន្ធលើប្រាក់ចំណូល ការិយបរិច្ឆេទបច្ចុប្បន្ន | **១១០.៥១៥** | **៤៤៣.២៧៦** | ៩៤.៤៣០ | ៣៨៤.៤២៥ |

ផ្អែកលើច្បាប់ស្តីពីសារពើពន្ធរបស់ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមានកាតពកិច្ចក្នុងការបង់ពន្ធ៖

- ៥% (២០២៤៖ ៥%) នៃបុព្វលាភធានារ៉ាប់រងដុលដែលទទួលបាននៅក្នុងឆ្នាំជាប់ពន្ធ ដែលទាក់ទងនឹងហានិភ័យនៃការធានារ៉ាប់រងហានិភ័យ ឬហានិភ័យធានារ៉ាប់រងបន្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា និង
- ចំពោះសកម្មភាពផ្សេងៗក្រៅពីការធានារ៉ាប់រង ឬធានារ៉ាប់រងបន្ត ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ២០% (២០២៤៖ ២០%) នៃប្រាក់ចំណេញជាប់ពន្ធ ឬពន្ធអប្បបរមា ១% នៃផលចំណូលផ្សេង ឬពន្ធណាមួយដែលមានតម្លៃខ្ពស់ជាង។

ចំណូលការប្រាក់ដែលបានមកពីការតម្កល់នៅធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុក្នុងស្រុក មិនត្រូវបានជាប់ពន្ធលើប្រាក់ចំណេញដោយអនុលោមតាមសារាចរលេខ ០០៣ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានពន្ធដារ ស្តីពីពន្ធលើប្រាក់ចំណេញ និងការប្រមូលពន្ធពីក្រុមហ៊ុនធានារ៉ាប់រង ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១១។

តួលេខក្នុងការផ្ទៀងផ្ទាត់រវាងចំណាយពន្ធ និងផលគុណនៃបុព្វលាភដុល ដោយអនុវត្តតាមអត្រាពន្ធរបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | ដុល្លារអាមេរិក | ពាន់រៀល |
| បុព្វលាភដុល | **២.២១០.៣១១** | **៨.៨៦៥.៥៥៧** | ១.៨៨៨.៦០១ | ៧.៦០១.៦១៩ |
| អត្រាអនុវត្តពន្ធក្នុងប្រទេសកម្ពុជាតាម អត្រា ៥% (២០២៤៖ ៥%) | **១១០.៥១៥** | **៤៤៣.២៧៦** | ៩៤.៤៣០ | ៣៨៤.៤២៥ |
| ចំណាយពន្ធសរុប | **១១០.៥១៥** | **៤៤៣.២៧៦** | ៩៤.៤៣០ | ៣៨៤.៤២៥ |

**១៨.** **ចំណាយពន្ធ** (ត)
(ខ) បំណុលពន្ធបច្ចុប្បន្ន

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | ដុល្លារអាមេរិក | ពាន់រៀល |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា | **១២.៩៧២** | **៥២.២១២** | ៣០.៨៦២ | ១២៦.០៧១ |
| ចំណាយពន្ធលើប្រាក់ចំណូល | **១១០.៥១៥** | **៤៤៣.២៧៦** | ៩៤.៤៣០ | ៣៨៤.៤២៥ |
| ពន្ធលើប្រាក់ចំណូលដែលបានបង់ | **(១០១.១៣៥)** | **(៤០៥.៦៥២)** | (១១២.៣២០) | (៤៥៧.២៥៥) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | **-** | **(១៣៧)** | - | (១.០២៩) |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ | **២២.៣៥២** | **៨៩.៦៩៩** | ១២.៩៧២ | ៥២.២១២ |

**១៩.** **ការលាតត្រដាងពីភាគីពាក់ព័ន្ធ**

(ក) ភាគី ដែលត្រូវបានចាត់ទុកថាជាភាគីពាក់ព័ន្ធរបស់ក្រុមហ៊ុន ប្រសិនបើភាគីនោះមានលទ្ធភាពគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោល ឬមានឥទ្ធិពលសំខាន់ៗ ក្នុងការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការ ឬផ្ទុយមកវិញ ឬ ប្រសិនបើក្រុមហ៊ុន និងភាគីទាំងនោះ ស្ថិតក្រោមការគ្រប់គ្រងតែមួយ ឬស្ថិតក្រោមឥទ្ធិពលសំខាន់រួម។ ភាគីពាក់ព័ន្ធ អាចជារូបវន្ត ឬនីតិបុគ្គល។

គណៈគ្រប់គ្រងសំខាន់ៗ របស់ក្រុមហ៊ុនរួមមានបុគ្គលទាំងឡាយណា(រួមបញ្ចូលទាំងអភិបាលទាំងអស់របស់ក្រុមហ៊ុន) ដែលមានសិទ្ធិអំណាច និងទំនួលខុសត្រូវក្នុងការរៀបចំផែនការ ដឹកនាំ និងគ្រប់គ្រងសកម្មភាពរបស់ក្រុមហ៊ុន ដោយផ្ទាល់ ឬដោយប្រយោល។

សំណងរួមមានទាំងអត្ថប្រយោជន៍ផ្សេងៗរបស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងសំខាន់ៗសម្រាប់ការិយបរិច្ឆេទដែលមានសមតុល្យ ៨០.១៥០ ដុល្លារអាមេរិក ឬស្មើនឹង ៣២១.៤៨២ រៀល (ឆ្នាំ២០២៤៖ ៥៨.៨០.០០០ ដុល្លារអាមេរិក ឬស្មើនឹង ២៣៩.៣៧៥.០០០ រៀល)។

(ខ) ក្រុមហ៊ុនមានប្រតិបត្តិការជាមួយនឹងភាគីពាក់ព័ន្ធក្នុងការិយបរិច្ឆេទនេះដូចខាងក្រោម៖

| | ២០២៥ | | ២០២៤ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | ដុល្លារអាមេរិក | ពាន់រៀល |
| <u>ក្រុមហ៊ុនពាក់ព័ន្ធ</u> | | | | |
| Chean Chheng Thai Group Co., Ltd | | | | |
| ការទូទាត់សងទៅក្រុមហ៊ុន | - | - | ១.៣០០.០០០ | ៥.២៣២.៥០០ |

ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធពណ៌នាខាងលើ គឺបានធ្វើឡើងដោយយោងតាមលក្ខណៈពាណិជ្ជកម្មធម្មតា និងមានការគិតអត្រាការប្រាក់ ៥% ជាប្រចាំឆ្នាំ។

## ២១. មូលធន និងការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### (ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ក្រុមហ៊ុនប្រឈមជាចម្បងទៅនឹងហានិភ័យឥណទាន ហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់ ហានិភ័យដើមទុន ហានិភ័យការធានា និងហានិភ័យធានារ៉ាប់រងបន្ត។ ព័ត៌មានស្តីពីការគ្រប់គ្រងការប្រឈមដែលពាក់ព័ន្ធមានដូចខាងក្រោម៖

(១) ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដោយសមភាគីមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យា។ ក្រុមហ៊ុនប្រឈមនឹងហានិភ័យឥណទានពីសមតុល្យនៅសល់ពីគណនីត្រូវទទួល។ គោលការណ៍របស់ក្រុមហ៊ុន គឺត្រួតពិនិត្យស្ថានភាពហិរញ្ញវត្ថុរបស់សមភាគីជាប្រចាំ ដើម្បីធានាថាក្រុមហ៊ុនប្រឈមនឹងហានិភ័យឥណទានទាបបំផុត។

ការប្រឈមចម្បងរបស់ក្រុមហ៊ុនចំពោះហានិភ័យឥណទាន កើតឡើងតាមរយៈគណនីធានារ៉ាប់រងត្រូវទទួលពីអតិថិជនរបស់ខ្លួន។ ក្រុមហ៊ុនគ្រប់គ្រងហានិភ័យឥណទានលើការលក់ដោយធានាថាអតិថិជនរបស់ខ្លួនមានជំហហិរញ្ញវត្ថុ និងប្រវត្តិឥណទានល្អ។ ក្រុមហ៊ុនក៏ស្វែងរកការវិនិយោគទ្រព្យសកម្មសាច់ប្រាក់ប្រកបដោយសុវត្ថិភាព និងដែលអាចចំណេញជាមួយស្ថាប័នហិរញ្ញវត្ថុដែលទទួលបានការទទួលស្គាល់។

ក្រុមហ៊ុនកំណត់ទ្រព្យសកម្មហិរញ្ញវត្ថុមិនអាចទូទាត់បាន នៅពេលដែលការទូទាត់តាមកិច្ចសន្យាហួសពេលកំណត់ ហើយនៅពេលដែលព័ត៌មានផ្ទៃក្នុង ឬខាងក្រៅបង្ហាញថា ទ្រព្យសកម្មហិរញ្ញវត្ថុ មិនអាចប្រមូលយកមកវិញបាន។ ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានលុបចោលនៅពេលដែលគ្មានការរំពឹងទុកសមហេតុផលស្តីពីការស្តារលំហូរសាច់ប្រាក់តាមកិច្ចសន្យា។

<u>ការប្រឈមចំពោះហានិភ័យឥណទាន និងទម្រង់នៃការប្រមូលផ្តុំហានិភ័យឥណទាន</u>

ការប្រឈមអតិបរមាទៅនឹងហានិភ័យឥណទានរបស់ក្រុមហ៊ុន តំណាងដោយតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុនីមួយៗ។

ក្រុមហ៊ុនមិនបានរំពឹងទុកថាសមតុល្យយោង ដែលបានកត់ត្រានៅចុងការិយបរិច្ឆេទនៃការរាយការណ៍នីមួយៗ នឹងខុសពីតម្លៃដែលនឹងត្រូវទទួលបានជាសារវន្តនោះទេ។

(២) ហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់

ហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់ កើតឡើងពីការគ្រប់គ្រងរបស់ក្រុមហ៊ុនទៅលើដើមទុនបង្វិល។ វាគឺជាហានិភ័យមួយ ដែលក្រុមហ៊ុននឹងជួបប្រទះផលលំបាកក្នុងការបំពេញនូវកាតព្វកិច្ចហិរញ្ញវត្ថុនៅពេលដែលដល់កាលកំណត់ត្រូវសង។

ក្រុមហ៊ុនគ្រប់គ្រងលំហូរសាច់ប្រាក់ពីប្រតិបត្តិការ និងភាពមានស្រាប់នៃមូលនិធិយ៉ាងសកម្ម ដើម្បីធានាបាននូវរាល់តម្រូវការរបស់ប្រតិបត្តិការ វិនិយោគ និងហិរញ្ញប្បទាន។ នៅក្នុងយុទ្ធសាស្ត្រនៃការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល ក្រុមហ៊ុនរក្សានូវកម្រិតសាច់ប្រាក់ និងសាច់ប្រាក់សមមូលគ្រប់គ្រាន់សម្រាប់គាំទ្រដល់សកម្មភាពប្រតិបត្តិការរបស់ក្រុមហ៊ុន។

## ២១. មូលធន និងការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

(៣) ហានិភ័យការធានា

ហានិភ័យការធានា រួមបញ្ចូលហានិភ័យដែលចំណាយលើសំណងច្រើនជាងការរំពឹងទុកដោយសារសំណងដោយចៃដន្យ និងភាពញឹកញាប់ ព្រមទាំងភាពធ្ងន់ធ្ងរ និងហានិភ័យនៃការផ្លាស់ប្តូរច្បាប់ ឬលក្ខខណ្ឌសេដ្ឋកិច្ច ឬឥរិយាបថដែលប៉ះពាល់ដល់ការកំណត់តម្លៃ និងលក្ខខណ្ឌនៃធានារ៉ាប់រង និងធានារ៉ាប់រងបន្ត។ ក្រុមហ៊ុនព្យាយាមកាត់បន្ថយហានិភ័យការធានា ដោយរក្សាសមតុល្យភាព និងការបែងចែកអាជីកម្មរវាងចំណាត់ថ្នាក់ជំនួញ និងដោយគោរពតាមគោលការណ៍ការធានា និងកំណត់ ការប៉ាន់ស្មានដោយប្រុងប្រយ័ត្ននៃសំវិធានធនសំណង និងស្តង់ដាកម្រិតខ្ពស់ដែលត្រូវបានអនុវត្តចំពោះសមត្ថកិច្ចរបស់អ្នកធានារ៉ាប់រងបន្ត។

(៤) ហានិភ័យធានារ៉ាប់រងបន្ត

ហានិភ័យធានារ៉ាប់រងបន្ត ទាក់ទងទៅនឹងហានិភ័យដែលស្ថានភាពហិរញ្ញវត្ថុនៃក្រុមហ៊ុន ធានារ៉ាប់រងបន្តដែលក្រុមហ៊ុនធានារ៉ាប់រងបន្តមានការគ្រប់គ្រងហានិភ័យលើការធានាមិនសមប្រកប ដូច្នេះវាអាចមានការពន្យារលើសមត្ថភាពក្នុងការទាមទារសំណងពីការធានារ៉ាប់រងបន្ត។ ដើម្បីកាត់បន្ថយហានិភ័យនេះ ក្រុមហ៊ុនបានវិភាគស្ថានភាពហិរញ្ញវត្ថុ និងពិចារណាលើចំណាត់ថ្នាក់ឥណទានរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្តដែលខ្លួនបានធ្វើប្រតិបត្តិការជាមួយ និងដាក់ជំនួញធានារ៉ាប់រងរបស់ខ្លួនជាមួយក្រុមហ៊ុនធានារ៉ាប់រងបន្តផ្សេងៗគ្នា។

(៥) ហានិភ័យ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ការប្រឈមមុខនឹងហានិភ័យធានារ៉ាប់រងរបស់ក្រុមហ៊ុន រួមមានទាំងដែនកំណត់នៃការរក្សាហានិភ័យ ការរៀបចំការធានារ៉ាប់រងបន្ត និងការប្រមូលផ្តុំនៃការប៉ះពាល់ចំពោះអ្នកធានារ៉ាប់រងបន្តបុគ្គល មិនត្រូវបានចាត់ទុកថាមានហានិភ័យជាសារវន្តនោះទេ។ ក្រុមហ៊ុនរក្សាកម្រិតហានិភ័យធានារ៉ាប់រងក្នុងកិច្ចសន្យានីមួយៗ ហើយហានិភ័យដែលលើស ត្រូវបានប្រគល់ឱ្យមានការរៀបចំការធានារ៉ាប់រងឡើងវិញជាមួយសមភាគី។ ពុំមានក្រុមហ៊ុនធានារ៉ាប់រងបន្តបុគ្គលដែលតំណាងឱ្យការប្រមូលផ្តុំនៃហានិភ័យចម្បងៗ ឬការស្តារឡើងវិញនោះទេ។ អាស្រ័យហេតុនេះ ការលាតត្រដាងពីបរិមាណលម្អិតនៃដែនកំណត់ពីការរក្សាហានិភ័យ រចនាសម្ព័ន្ធការធានារ៉ាប់រងបន្ត និងការប៉ះពាល់ជាមួយក្រុមហ៊ុនធានារ៉ាប់រងបន្តនីមួយៗ មិនត្រូវបានបង្ហាញនោះទេ។

## ២១. ពន្ធយថាភាព

ប្រព័ន្ធពន្ធដារនៅក្នុងប្រទេសកម្ពុជា ត្រូវបានបែងចែកជាច្រើនប្រភេទ និងបទប្បញ្ញត្តិពឹងផ្អែកលើការបកស្រាយ។ ជានិច្ចកាលការបកស្រាយផ្សេងៗគ្នាកើតមានឡើងនៅក្នុងចំណោមអាជ្ញាធរពន្ធ និងយុត្តាធិការ។ ពន្ធត្រូវបានត្រួតពិនិត្យឡើងវិញ និងស៊ើបអង្កេតដោយអាជ្ញាធរមួយចំនួនដែលទទួលការអនុញ្ញាតដោយច្បាប់ក្នុងការដាកពិន័យធ្ងន់ធ្ងរ ដាក់ទណ្ឌកម្ម និងពិន័យជាការប្រាក់។ កត្តាទាំងនេះហើយផ្សេងៗដែលអាចធ្វើឱ្យហានិភ័យពន្ធដារនៅក្នុងព្រះរាជាណាចក្រកម្ពុជាខ្លាំងជាងប្រទេសដទៃទៀត។ គណៈគ្រប់គ្រង មានការជឿជាក់ថា ខ្លួនបានបង់បំណុលពន្ធគ្រប់គ្រាន់ដោយផ្អែកលើការបកស្រាយបទប្បញ្ញត្តិពន្ធរបស់ខ្លួន។ ទោះបីយ៉ាងនេះក្តីសមត្ថកិច្ចពន្ធពាក់ព័ន្ធអាចមានការបកស្រាយខុសៗគ្នា ហើយផលប៉ះពាល់អាចមានជាសារវន្ត។

## ២០. មូលធន និងការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

### (ក) ការគ្រប់គ្រងមូលធន

គោលបំណងចម្បងរបស់ក្រុមហ៊ុនក្នុងការគ្រប់គ្រងមូលធន គឺដើម្បីធានាឱ្យបានថា ក្រុមហ៊ុនអាចបន្តប្រតិបត្តិការរបស់ខ្លួន ដោយឈរលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម ហើយស្របពេលជាមួយគ្នានេះធ្វើឱ្យមានកំណើនផលលាភដល់ភាគហ៊ុនិក។ ពុំមានការផ្លាស់ប្តូរយុទ្ធសាស្ត្រទូទៅរបស់ក្រុមហ៊ុនតាំងពី ការិយបរិច្ឆេទមុនទេ។

ក្រុមហ៊ុនត្រូវបានតម្រូវឱ្យរក្សាកម្រិតសាធនភាព យ៉ាងតិចកម្រិតអប្បបរមានៃ ១២០% ដោយកំណត់ដោយនិយ័តករធានារ៉ាប់រងកម្ពុជា ("ន.ធ.ក") និងក្រុមហ៊ុនរក្សាកម្រិតសាធនភាពដែលបានកំណត់នៃ ១២០% គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។ នេះជាគោលនយោបាយក្រុមហ៊ុន ដើម្បីរក្សាដើមទុនគ្រប់គ្រាន់ និងបំពេញតម្រូវការដើមទុនអប្បបរមា ដោយអនុលោមតាមប្រកាសលើកម្រិតសាធនភាព នៃក្រុមហ៊ុនធានារ៉ាប់រងចេញផ្សាយដោយ ន.ធ.ក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣។

កម្រិតសាធនភាពរបស់ក្រុមហ៊ុនត្រូវបានគណនាដូចខាងក្រោម៖

| | | ២០២៥ | | ២០២៤ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| មូលធនសរុប* | **៧.៦៧៣.៣០៥** | **៣០.៧៩២.៩៧៣** | ៧.២៦០.៨៨០ | ២៩.២២៥.០៤២ |
| ដើមទុនអប្បបរមាបទប្បញ្ញត្តិ** | **៣.៥០០.០០០** | **១៤.០០០.០០០** | ៣.៥០០.០០០ | ១៤.០០០.០០០ |
| គម្លាតសាធនភាព (>១២០%) | | **២១៩%** | | ២០៧% |

* មូលធនសរុប ប្រាក់បញ្ញើស្របតាមបទប្បញ្ញត្តិសុទ្ធជាមួយធនាគារជាតិនៃកម្ពុជា
** ៥០% នៃដើមទុនចុះបញ្ជីសម្រាប់ការិយបរិច្ឆេទប្រតិបត្តិការដំបូង

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ក្រុមហ៊ុនកំពុងអនុលោមតាមតម្រូវការគម្លាតសាធនភាព។

### (ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

គោលបំណងនៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គឺដើម្បីបង្កើនប្រសិទ្ធភាពតម្លៃសម្រាប់ភាគហ៊ុនិក ហើយទន្ទឹមគ្នានេះដែរ ក៏ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលអាចកើតឡើង ដោយសារការប្រែប្រួលនៃទីផ្សារហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល មានទំនួលខុសត្រូវលើការកំណត់គោលបំណង និងគោលការណ៍មូលដ្ឋាននៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ ហេតុនេះហើយ គណៈគ្រប់គ្រងបង្កើតគោលការណ៍លម្អិតដូចជាកម្រិតសិទ្ធិអំណាច ទំនួលខុសត្រូវលើការត្រួតពិនិត្យ ការកំណត់ និងវាស់វែងអត្តសញ្ញាណហានិភ័យ និងដែនកំណត់នៃការប្រឈមដោយអនុលោមតាមគោលបំណង និងគោលការណ៍មូលដ្ឋានដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

## ២២. ការអនុវត្តនូវស្តង់ដាគណនេយ្យនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាថ្មី

### ២២.១ ស្តង់ដាថ្មី និងការធ្វើវិសោធនកម្មស្តង់ដា និងការបកស្រាយ

វិសោធនកម្មចំពោះស្តង់ដាគណនេយ្យ CIFRS ដែលមានស្រាប់ខាងក្រោមបានចូលជាធរមានសម្រាប់ពេញមួយការិយបរិច្ឆេទដែលចាប់ផ្តើមនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៥៖

- កង្វះខាតនៃការផ្លាស់ប្តូរ - វិសោធនកម្មលើ CIAS ២១

ការធ្វើវិសោធនកម្មនេះ ពុំមានផលប៉ះពាល់ចម្បងណាមួយទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ នេះឡើយ។

### ២២.២ ស្តង់ដាដែលបានចេញផ្សាយ ប៉ុន្តែពុំទាន់មានប្រសិទ្ធភាព

ស្តង់ដាថ្មី និងការធ្វើវិសោធនកម្មស្តង់ដា និងការបកស្រាយ ដែលបានចេញផ្សាយ ប៉ុន្តែពុំទាន់ចូលជាធរមាន កំពុងត្រូវបានវាយតម្លៃដោយធនាគារ ដើម្បីកំណត់ពីផលប៉ះពាល់ទៅលើរបាយការណ៍ហិរញ្ញវត្ថុ។

- វិសោធនកម្មចំពោះការធ្វើចំណាត់ថ្នាក់ និងការវាស់វែងនៃឧបករណ៍ហិរញ្ញវត្ថុ - វិសោធនកម្មចំពោះ CIFRS ៩ និង CIFRS ៧

  វិសោធនកម្មទាំងនេះ មានប្រសិទ្ធភាពសម្រាប់ពេញមួយការិយបរិច្ឆេទចាប់ផ្តើមនៅ ឬក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០២៦។ ការអនុវត្តមុនត្រូវបានអនុញ្ញាតជាមួយនឹងជម្រើសចំពោះការអនុវត្តជាមុន នូវវិសោធនកម្មនៃការធ្វើចំណាត់ថ្នាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុ និងការលាតត្រដាងពាក់ព័ន្ធតែប៉ុណ្ណោះ។

  បច្ចុប្បន្ននេះ ក្រុមហ៊ុន មិនមានបំណងអនុវត្តវិសោធនកម្មជាមុននោះទេ។

- កិច្ចព្រមព្រៀងទិញថាមពល - វិសោធនកម្មចំពោះ CIFRS ៩ និង CIFRS ៧

  នៅខែធ្នូ ឆ្នាំ២០២៤ IASB បានចេញផ្សាយ កិច្ចសន្យាយោងទៅលើថាមពលអគ្គិសនីអាស្រ័យលើធម្មជាតិ (វិសោធនកម្មចំពោះ CIFRS ៩ និង CIFRS ៧)។ វិសោធនកម្មមានប្រសិទ្ធភាពសម្រាប់របាយការណ៍ប្រចាំឆ្នាំដែលចាប់ផ្តើមនៅ ឬក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០២៦។ ការអនុវត្តមុនត្រូវបានអនុញ្ញាត ប៉ុន្តែត្រូវធ្វើការលាតត្រដាង។

  ការធ្វើវិសោធនកម្មនេះ មិនត្រូវបានគេរំពឹងថា នឹងមានផលប៉ះពាល់ជាសារវន្តទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននោះទេ។

- ការកែលម្អប្រចាំឆ្នាំចំពោះស្តង់ដាគណនេយ្យ CIFRS - លេខ ១១

  នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៤ IASB បានចេញផ្សាយការកែលម្អប្រចាំឆ្នាំចំពោះស្តង់ដាគណនេយ្យ CIFRS - លេខ ១១។ ការចេញផ្សាយនោះមានវិសោធនកម្មចំពោះ CIFRS ១ CIFRS ៧ CIFRS ៩ CIFRS ១០ និង CIAS ៧។

  ការកែលម្អនេះ មិនត្រូវបានគេរំពឹងថា នឹងមានផលប៉ះពាល់ជាសារវន្តទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននោះទេ។

## ២២. ការអនុវត្តនូវស្តង់ដាគណនេយ្យនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាថ្មី

### ២២.២ ស្តង់ដាដែលបានចេញផ្សាយ ប៉ុន្តែពុំទាន់មានប្រសិទ្ធភាព (ត)

- CIFRS ១៩ ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលគ្មានគណនេយ្យភាពសាធារណៈ៖ ការលាតត្រដាង

  នៅខែឧសភា ឆ្នាំ២០២៤ IASB បានចេញផ្សាយ CIFRS ១៩ ដែលអនុញ្ញាតឱ្យអង្គភាពដែលទទួលបានសិទ្ធិជ្រើសរើសអនុវត្តការកាត់បន្ថយតម្រូវការលាតត្រដាង ខណៈបន្តអនុវត្តទៅលើតម្រូវការនៃការទទួលស្គាល់ ការវាស់វែង និងបទបង្ហាញនៅក្នុងស្តង់ដាគណនេយ្យ CIFRS ផ្សេងទៀត។ ដើម្បីបានសិទ្ធិនេះ នៅចុងការិយបរិច្ឆេទនៃរបាយការណ៍ អង្គភាពត្រូវតែជាក្រុមហ៊ុនបុត្រសម្ព័ន្ធដូចដែលបានកំណត់នៅក្នុង CIFRS ១០ មិនអាចមានគណនេយ្យភាពសាធារណៈ និងត្រូវតែមានក្រុមហ៊ុនមេ (ចុងក្រោយបង្អស់ ឬដោយផ្ទាល់) ដែលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម ដែលអាចប្រើប្រាស់ជាសាធារណៈដោយអនុលោមតាមស្តង់ដាគណនេយ្យ CIFRS។ CIFRS ១៩ នឹងចូលជាធរមានសម្រាប់របាយការណ៍ប្រចាំឆ្នាំដែលចាប់ផ្តើមនៅ ឬក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០២៧ ជាមួយនឹងការអនុញ្ញាតឱ្យអនុវត្តមុន។

- CIFRS ១៨ បទបង្ហាញ និងការលាតត្រដាងក្នុងរបាយការណ៍ហិរញ្ញវត្ថុ

  នៅខែមេសា ឆ្នាំ២០២៤ IASB បានអនុម័តទៅលើ IFRS ១៨ ដែលជំនួសឱ្យ IAS ១ 'ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ'។ ទោះបីជា IFRS ១៨ រួមបញ្ចូលនូវតម្រូវការជាច្រើនរបស់ IAS ១ ក៏ដោយស្តង់ដានេះបានណែនាំនូវតម្រូវការថ្មីសម្រាប់រចនាសម្ព័ន្ធរបាយការណ៍ហិរញ្ញវត្ថុឱ្យកាន់តែប្រសើរឡើង និងដើម្បីផ្តល់ព័ត៌មានលម្អិត និងមានប្រយោជន៍បន្ថែមទៀតដល់វិនិយោគិនរួមទាំង៖

  - សរុបរងថ្មីចំនួនពីរដែលបានកំណត់ក្នុងរបាយការណ៍ចំណេញ ឬខាតគឺ (១) ចំណេញប្រតិបត្តិការ និង (២) ចំណេញ ឬខាតមុនការផ្តល់ហិរញ្ញប្បទាន និងពន្ធលើប្រាក់ចំណូល
  - ការធ្វើចំណាត់ថ្នាក់នៃចំណូល និងចំណាយទាំងអស់នៅក្នុងរបាយការណ៍ចំណេញ ឬខាតតែមួយក្នុងចំណោមការចាត់ថ្នាក់ប្រាំប្រភេទ
  - តម្រូវការថ្មីដើម្បីបង្ហាញនូវវិធាននៃការអនុវត្តដែលកំណត់ដោយគណៈគ្រប់គ្រង និង
  - ការកែលម្អគោលការណ៍ទាក់ទងនឹងការប្រមូលផ្តុំ និងការបំបែកព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងកំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ។

  តម្រូវការនៃការលាតត្រដាងមួយចំនួនដែលមានពីមុននៅក្នុង IAS ១ ត្រូវបានផ្ទេរទៅ IAS ៨ ដោយគ្មានការផ្លាស់ប្តូរជាសារវន្តណាមួយឡើយ។ ការអនុវត្តនេះ ត្រូវបានអនុវត្តជាពិសេសចំពោះការបង្ហាញអំពីគោលនយោបាយគណនេយ្យ និងប្រភពនៃភាពមិនច្បាស់លាស់ពីការប៉ាន់ស្មាន។ ជាលទ្ធផលនៃការផ្លាស់ប្តូរទាំងនេះ IAS ៨ នឹងត្រូវប្តូរឈ្មោះទៅជា 'មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ' ។ ការបោះពុម្ពផ្សាយនៃ IFRS ១៨ ក៏បណ្តាលឱ្យមានវិសោធនកម្មជាបន្តបន្ទាប់ចំពោះស្តង់ដាគណនេយ្យ IFRS ផ្សេងទៀត រួមទាំង IAS ៧ ផងដែរ។

  IFRS ១៨ មានប្រសិទ្ធភាពជាធរមានសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើមនៅ ឬក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០២៧ ហើយមានការអនុញ្ញាតពីឱ្យអនុវត្តមុន។ IFRS ១៨ នឹងត្រូវបានអនុវត្តត្រឡប់មកវិញជាមួយនឹងបទប្បញ្ញត្តិអន្តរកាលជាក់លាក់។

## ២២. ការអនុវត្តនូវស្តង់ដាគណនេយ្យនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាថ្មី

### ២២.២ ស្តង់ដាដែលបានចេញផ្សាយ ប៉ុន្តែពុំទាន់មានប្រសិទ្ធភាព (ត)

បច្ចុប្បន្ន ក្រុមហ៊ុនកំពុងធ្វើការដើម្បីកំណត់អត្តសញ្ញាណនៃផលប៉ះពាល់ទាំងអស់ពី IFRS ១៨ ដែលនឹងមាននៅលើរបាយការណ៍ហិរញ្ញវត្ថុចម្បង និងកំណត់សម្គាល់ទៅលើរបាយការណ៍ហិរញ្ញវត្ថុ។

ស្តង់ដាថ្មីផ្សេងៗ និងការធ្វើវិសោធនកម្មស្តង់ដា និងការបកស្រាយដែលមិនបានអនុវត្តនៅក្នុងការិយបរិច្ឆេទបច្ចុប្បន្ន គឺមិនត្រូវបានលាតត្រដាង ព្រោះមិនត្រូវបានគេរំពឹងថា នឹងមានផលប៉ះពាល់ជាសារវន្តទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននោះទេ។

## ២៣. ការចាត់ថ្នាក់លើឧបករណ៍ហិរញ្ញវត្ថុ

តារាងខាងក្រោមផ្តល់នូវការវិភាគលើឧបករណ៍ហិរញ្ញវត្ថុដែលវាស់វែងតាមថ្លៃដើមបានរំលស់៖

| | | ២០២៥ | | ២០២៤ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ | **៦៩៥.៤១៧** | **២.៧៩០.៧០៨** | ២៥៣.៤១៧ | ១.០២០.០០៣ |
| សាច់ប្រាក់ និងសមតុល្យនៅក្នុងធនាគារ | **៨.០៧៧.៥៤៧** | **៣២.៤១៥.១៩៦** | ៧.៨៤៤.៧១៩ | ៣១.៥៧៤.៩៩៤ |
| | **៨.៧៧២.៩៦៤** | **៣៥.២០៥.៩០៤** | ៨.០៩៨.១៣៦ | ៣២.៥៩៤.៩៩៧ |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| បំណុលភតិសន្យា | **៧២.៣២៣** | **២៩០.២៣២** | ២១.៣៣៥ | ៨៥.៨៧៤ |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | **៩៤៣.៦៨១** | **៣.៧៨៦.៩៩១** | ៧១៦.៩២១ | ២.៨៨៥.៦០៧ |
| | **១.០១៦.០០៤** | **៤.០៧៧.២២៣** | ៧៣៨.២៥៦ | ២.៩៧១.៤៨១ |

## ២៤. ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទនៃរបាយការណ៍

ពុំមានការកែតម្រូវ ឬព្រឹត្តិការណ៍មិនបានកែតម្រូវជាសារវន្តណាមួយដែលបានកើតឡើងបន្ទាប់ពីចុងការិយបរិច្ឆេទនៃការរាយការណ៍ និងកាលបរិច្ឆេទនៃការអនុម័តទៅលើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ដែលតម្រូវឱ្យធ្វើការកែតម្រូវ ឬធ្វើការលាតត្រដាង ដែលត្រូវបានធ្វើឡើងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះឡើយ។

East Insurance Plc.

**ក្រុមហ៊ុន អេស អិនស្ទួរិន ភីអិលស៊ី**

**បានឃើញ និងឯកភាពខ្លឹមសារខាងលើ**

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០២៦

**ក្រុមហ៊ុន អេស អិនស្ទួរិន ភីអិលស៊ី**

**ប្រធានក្រុមប្រឹក្សាភិបាល**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន អេស អិនស្ទួរិន ភីអិលស៊ី EAST INSURANCE PLC KINGDOM OF CAMBODIA

**TAN WENCHAO**

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០២៦

**ក្រុមហ៊ុន អេស អិនស្ទួរិន ភីអិលស៊ី**

**អគ្គនាយក**

**HUANG YOUFENG**

**EAST INSURANCE PLC**
The 6th Floor, No.724, Norodom Boulevard (41), Phum 10, Sangkat Tonle Bassac, Khan Chamkamorn, Phnom Penh
Office: +855 (0) 23929988 , E-mail:info@east-insurance-plc.com